# បណ្ដាំតាមាស

អារម្ភកថា និងបោះពុម្ពផ្សាយ
ដោយ
បណ្ឌិត **ឃីង ហុកឌី**



ភ្នំឧដុង្គមានជ័យ

( RECOMMANDATIONS DE TA MEAS )
Edition présentée et annotée
par
KHING Hoc Dy


បណ្ណាគារ អង្គរ
Editions Angkor

ស្នាដៃលោកតាមាសនេះគឺជាពាក្យបណ្ដាំឱ្យកូនចៅក្រោយយកទុកជាគតិដកស្រង់ពីបទពិសោធន៍របស់លោកនៅសតវត្សទី១៩ និងដើមសតវត្សទី២០ ។ រឿងនេះទៀតសោតគឺកញ្ចក់ឆ្លុះមើលសង្គមនិងប្រវត្តិសាស្ត្រស្រុកខ្មែរនៅសម័យនោះ។ តាមាសបានរស់នៅក្នុងរាជ្យស្ដេចអង្គចន្ទ , ក្សត្រីអង្គមី,ស្ដេចអង្គឌួង,ស្ដេចនរោត្តមនិងដើមរាជ្យស្ដេច ស៊ីសុវត្ថិបានសេចក្ដីថាលោកបានស្គាល់ជីវភាពប្រជាជនខ្មែរក្នុងរជ្ជកាល ៥រាជ្យស្ដេចខ្មែរ ។ នេះជាសក្ខីភាពនៃការរស់នៅក្នុងកំណាត់ កាលប្រហែល ៨០ ឆ្នាំ គឺបង្ហាញពីប្រវត្តិសាស្ត្រខ្មែរយើងតាមរយៈតាមាសជាប្រជាជនម្នាក់ដែល គ្មានទំនោរ នយោបាយ ។ លោកចង់ផ្ដាំដល់ទៅជនានុជនមាតុភូមិឱ្យយល់ដឹងពីភាពតោកយ៉ាក, ទុរ្ភិក្ស,សង្គ្រាមរាំងជល់, ការព្រាត់ប្រាសគ្រួសារបងប្អូនប្ដីប្រពន្ធកូនចៅក្នុងសម័យកាលមួយដ៏វែង រហូតមកដល់ សម័យ អាណាព្យាបាលបារាំងសែស ។ ដោយអត្ថបទបណ្ដាំតាមាសនេះជាអត្ថបទ នៅដើមសតវត្សទី២០ នៅពេលដែលប្រទេសយើងចាប់មានអក្សរសិល្ប៍ជាលើកទី១ដែរ គឺនៅឆ្នាំ ១៩០៧_១៩០៨ ។ រោងពុម្ពអក្សរខ្មែរនេះបានចូលមកភ្នំពេញដំបូងគឺសម្រាប់បោះពុម្ពឯកសាររដ្ឋបាល បារាំង, សៀវភៅធម៌គ្រិស្ដសាសនា និងអត្ថបទសិក្សា នៃស្ថាប័នវិទ្យាសាស្ត្រដូចជាសាលា បារាំងចុងបូព៌ាប្រទេសជាដើម ។ រឿងបណ្ដាំតាមាសនេះជាអត្ថបទអក្សរសិល្ប៍បោះពុម្ពទី១បន្ទាប់ពី ការនាំចូលនូវបច្ចេកទេសថ្មីទំនើបនេះ ព្រោះដើមឡើយយើងធ្លាប់តែចម្លងដោយដៃលើក្រដាសឬចារ លើស្លឹកត្នោត, ស្លឹករឹត ។ល។

**បណ្ណាគារ អង្គរ**

**ផ្ទះលេខ 143Eo ផ្លូវខេមរភូមិន្ទ (130) ភ្នំពេញ**

9789995059613

# បណ្តាំតាមាស

អារម្ភកថានិងបោះពុម្ពផ្សាយ

ដោយ

បណ្ឌិត ឃីង ហុកឌី


បណ្ណាគារ អង្គរ

2007

បោះពុម្ពផ្សាយដោយ

**បណ្ណាគារ អង្គរ**

រក្សាសិទ្ធិ

©Copyright

ISBN-13:978-99950-59-61-3

2007

# អារម្ភកថា

មាស (១៨២៨-១៩១០?)

តា មាស កើត នៅ ឆ្នាំ ជូត សំរិទ្ធិស័ក ចុល្លសករាជ ១១៩០ ត្រូវ នឹង គ.ស. ១៨២៨,[1] បិតា លោក មាន ងារ ជា បាឡាត់ ខែត្រ លង្វែក ដែល មាន ដីតា ជា ចៅហ្វាយ ស្រុក, មាតា លោក បាន ទទួល អនិច្ចកម្ម នៅ ពេល ដែល យួន ចូល វាយ លុកបន្ទាយ លង្វែក ហើយ បង ប្អូន ប្រុស លោក ៣ នាក់ បាន ស្លាប់ ក្នុង សង្គ្រាម ដែរ។ យើងមិន ដឹង ថា លោក អនិច្ចកម្ម នៅ ឆ្នាំ ណា ទេ តែ យើង ដឹង ថា គាត់ រស់ រហូតមកដល់ ឆ្នាំគ.ស.១៩០៧[2] ជាឆ្នាំ ដែល គាត់ បាន បញ្ចប់ ស្នាដៃ «រឿង បន្ទាំ តា មាស» ។ តាម យើងស្មាន លោកប្រហែល ចូល មរណកាល នៅរវាង ចុង ទសវត្ស ទី១[illegible] នៃសតវត្សទី២០ ។ ស្នាដៃ លោកគឺ ជា ពាក្យ បណ្តាំ ឲ្យ កូន ចៅ ក្រោយ យក

---

[1] «នាម ខ្ញុំ ឈ្មោះ មាស ជា ចាស់ ព្រឹឝាចារីយ៍ អាយុស្ម ជាង ៨០ ឆ្នាំ ប្ល័យ កើតក្នុង ឆ្នាំ ជូតសំរិទ្ធិស័ក្យចុលស័ករាជ១១៩០ បើគិតជាស័ករាជបារាំងត្រូវ ថែម ឡែក១ ទៀតទើបត្រូវនិង ឆ្នាំ១៨២៨ តែង ជាពាកបន្ទាំម នេះទុកឲ្យ កូន ចៅនៅឯក្រោយ ចូល ចាំម គ្រប់គ្នាត់ទៅ» ។ *រឿងបន្ទាំតាមាស*, ទំព័រ ៣ (រក្សាអក្ខរាវិរុទ្ធដើម) ។

[2] «តែងក្នុង ចុលសករាជ១២៦៩ ឆ្នាំមមែ នព្វស័ក្យកាល តា អាយុស្ម បាន ៨០ ឆ្នាំ ប្ល័យ ហើ្យ» ។ *រឿងបន្ទាំមតាមាស*, ភ្នំពេញ, ១៩០៨, ទំព័រ,៤០ ។ ចំពោះសម្រង់នានា យើងសូម គោរពតាម អក្ខរាវិរុទ្ធដើមរបស់ អ្នកនិពន្ធនិងតាមសម័យនិមួយៗ ដោយ រក្សា ទុក ភាព ដើម ហើយ នឹង ចង់ ទុក ឲ្យ និរុទ្ធវិជ្ជាវិទូ យើង សិក្សា បន្ត ទៅ ទៀត ជា ប្រវត្តិ អក្សរសិល្ប៍ និង ភាសា ខ្មែរ យើង ។ ដូច នេះ សូម អ្នក អាន , អ្នក សិក្សា និង លោកគ្រូអ្នកគ្រូអធិប្បាយ បន្ថែម ទៀតផង ។

ទុក ជា គតិ ដក ស្រង់ ពី បទ ពិសោធន៍ របស់ លោក នៅ សតវត្ស ទី ១៩ និង ដើម សតវត្ស ទី ២០ ។ រឿង នេះ ទៀត សោត គឺ ជា កញ្ចក់ ឆ្លុះ មើល សង្គម និង ប្រវត្តិសាស្ត្រ ស្រុក ខ្មែរ នៅ សម័យ នោះ ។ តាមាស បាន រស់ នៅ ក្នុង រាជ្យ ស្តេច អង្គចន្ទ, ក្សត្រី អង្គមុី, ស្តេច អង្គឌួង, ស្តេច នរោត្តម និង ដើម រាជ្យ ស្តេច ស៊ីសុវត្ថិ បាន សេចក្តី ថា លោក បាន ស្គាល់ ជីវភាព ប្រជាជន ខ្មែរ ក្នុង រជ្ជកាល ៥ រាជ្យ ស្តេច ខ្មែរ ។ នេះ ជា សក្ខីភាព នៃ ទិដ្ឋភាព ស្តីពី ការ រស់ នៅ ក្នុង កំណត់ កាល ប្រហែល ៨០ ឆ្នាំ ពោល គឺ បង្ហាញ ពី ប្រវត្តិសាស្ត្រ និង សង្គម ខ្មែរ យើង តាម រយៈ តាមាស ជា ប្រជាជន ម្នាក់ ដែល គ្មាន ទំនោរ នយោបាយ ។ លោក ចង់ ផ្តាំ ទៅ ជនានុជន ក្នុង មាតុភូមិ ឲ្យ យល់ ដឹង ពី ភាព តោកយ៉ាក, ទុរ្ភិក្ស, សង្គ្រាម រាំងជល់, ការ ព្រាត់ ប្រាស គ្រួសារ បង ប្អូន ប្តី ប្រពន្ធ កូន ចៅ ក្នុង សម័យ កាល មួយ ដ៏ វែង រហូត មក ដល់ សម័យ អាណាព្យាបាល បារាំងសែស ។ ដោយ អត្ថបទ បណ្តាំ តាមាស នេះ ជា អត្ថបទ នៅ ដើម សតវត្ស ទី ២០ នៅ ពេល ដែល ប្រទេស យើង ចាប់ មាន អក្សរ ពុម្ព ខ្មែរ ដំបូង ហើយ រោង ពុម្ព នេះ ទៀត សោត បាន ចាប់ ផ្តើម បោះពុម្ព អត្ថបទ អក្សរសិល្ប៍ ជា ដំបូង បង្អស់ ដែរ គឺ នៅ នា ឆ្នាំ ១៩០៧-១៩០៨ ។ រោង ពុម្ព អក្សរ ខ្មែរ នេះ បាន ចូល មក ភ្នំពេញ ដំបូង គឺ សម្រាប់ បោះពុម្ព ឯកសារ រដ្ឋបាល បារាំង[3], គ្រិស្តសាសនា និង ស្ថាប័ន វិទ្យាសាស្ត្រ ដូច ជា សាលា បារាំង ចុង បូព៌ា ប្រទេស ជា ដើម ។ [4]រឿង បណ្តាំ តាមាស នេះ ជា អត្ថបទ ផ្សាយ អក្សរសិល្ប៍ ទី ១ បន្ទាប់ ពី ការ នាំ ចូល នូវ បច្ចេកទេស ថ្មី នៃ ការ បោះពុម្ព តាម វិធី ទំនើប ព្រោះ ដើម ឡើយ យើង

[3]កម្មវិធីបុណ្យសម្ភោធន៍វិហារព្រះកែវរតនារាមក្នុងព្រះបរមរាជវាំងភ្នំពេញ នាឆ្នាំ១៩០៣

[4]សូមអាន Khing Hoc Dy, *Ecrivains et expressions littéraires du Cambodge au XXème siècle*, Paris, L'Harmattan, 1993, p. 3-4; "Khmer Literature and Publications", *Bayon Pearnik*, Issue 70 June 2002 , p. 8 and 27, Issue 71 July 2002, p. 8 and 27 (Written by Dr. khing Hoc Dy CNRS Translated by Damien Morrison)



ធ្លាប់ តែ ចម្លង ដោយ ដៃ លើ ក្រដាស ឬ ចារ លើ ស្លឹក ត្នោត, ស្លឹករឹត ។ល។ តាម ការ ស្រាវ ជ្រាវ យើង អាច សន្និដ្ឋាន បាន ថា រឿង បណ្តាំតា មាស នេះ បាន បដិសន្ធិ ឡើង ដោយ មាន ការ ឧបត្ថម្ភ ពី លោក អាដេម៉ារឡឺ ក្លែរ (Adhémard Leclère) [5]ជា អតីត រ៉េស៊ីដង់ បារាំង ប្រចាំ ប្រទេស កម្ពុជា ។

អត្ថបទ នេះ យើង រក ឃើញ មួយ ច្បាប់ នៅ បណ្ណាល័យ សាលា បារាំង ចុង បូព៌ា ប្រទេស ក្រុង ប៉ារីស[6] និង មួយ ច្បាប់ ទៀត រក្សា នៅ បណ្ណាល័យ ជាតិ ក្រុង ប៉ារីស[7] ប្រទេស បារាំង គឺ ជា អត្ថបទ មាន ចំនួន ៤០ ទំព័រ ដែល បាន បោះពុម្ព ផ្សាយ រវាង ឆ្នាំ ១៩០៨[8] មាន ចំនួន ១០.០០០ ច្បាប់ ។ ច្បាប់ ចុង ក្រោយ នេះ យើង ឃើញ មាន ចំណារ ដោយ ដៃ នៅ លើ ទំព័រ ដើម ជិត ចំណង ជើង ថា «អាដេម៉ារឡឺ

[5]Adhémard Leclère បាន ទុក ស្នាដៃ សំខាន់ មួយ គឺ *Histoire du Cambodge depuis le 1er siècle de notre ère*, Paris, Guethner, 1914. សៀវភៅ នេះបានបកប្រែជាភាសាខ្មែរដោយទេពម៉េងឃានហៅទិឃាយុ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជរហូតមក*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៦(បោះពុម្ពលើកទី២) ។

[6]ចុះលេខ CAM.HIST.ANC.2

[7]ចុះលេខ 8° 02 374

[8]ក្នុងការបោះពុម្ពនេះគ្មានទីកន្លែងនិងកាលបរិច្ឆេទទេតែដោយយើងយោងទៅតាមសំនេរតាមាសគឺគាត់បានសរសេរចប់នៅចុល្លសករាជ១២៦៩ឆ្នាំមមែនព្វស័កគឺត្រូវនិងគ.ស.១៩០៧(នៅទំព័រ៤០ចែងថា÷ «តែងក្នុងចុលស័ករាជ ១២៦៩ឆ្នាំមមែនព្វស័ក្សកាលតាអាយុស បាន៨០ឆ្នាំប៉្ល្យហ្មើ ។ »)។ ហេតុនេះហើយបានជាយើងហ៊ានសន្និដ្ឋានថាអត្ថបទនេះបោះពុម្ពរវាងឆ្នាំ១៩០៧-១៩០៨ ។ សូមអាន ឌ.គាម, *ប្រតិទិន១០៦ឆ្នាំសុរិយគតិនិងចន្ទគតិ*, ភ្នំពេញ, ១៩៦៤, ទំព័រ ៦៣ ។

ក្លែរ»[9] ។ ហេតុនេះហើយ បានជាយើងហ៊ានសន្និដ្ឋាន ថាមាន លោក អាដេម៉ារឡឺក្លែរ បាន ជួយ ទំនុកបំរុងក្នុងការបោះ ពុម្ព ផ្សាយ ស្នា ដៃ តា មាស ដើម្បី សរសើររដ្ឋបាល អាណាព្យាបាល បារាំង ផង ដែរ ។ អក្ខរាវិរុទ្ធនាទសវត្សទី១នៃសតវត្សទី២០គ្មានឯកភាព ទេ គឺ កវីអ្នកនិពន្ធសរសេរ ចារ ស្នាដៃខ្លួនតាម ការអានពាក្យ គឺឥត បាន គោរពនិរុទ្ធសាស្ត្រ ឬ ឫសពាក្យ និមួយៗ ឡើយ ។ ស្នាដៃ នេះ បាន តែងនិង ចងក្រងមុនការបង្កើតវចនានុក្រមផ្លូវការដែល បានបដិសន្ធិឡើង ចាប់តាំងតែពីឆ្នាំ១៩៣៨[10]ពោលគឺចាប់ពី ពេល នោះ ហើយ ដែល អ្នកប្រាជ្ញ ភាសាខ្មែរ ជាពិសេស គឺ ព្រះសង្ឃ បាន ចង អក្ខរាវិរុទ្ធ ឲ្យ មាន ឯកភាព មាំ មួន តែ នៅ តែ មានពាក្យ ខ្លះ ទៀត អាច សរសេរ បាន ២ បែប[11] នៅ ឡើយ ។ ដូច នេះ ចំពោះអក្ខរាវិរុទ្ធខ្មែរមិនទាន់បិទទ្វារនៃការពិភាក្សានិងការ ស្រាវជ្រាវនៅឡើយ ទេពិតមែន តែ វចនានុក្រម ជា បញ្ញត្តិ មួយ បង្ខំ យើង ឲ្យ ធ្វើ តាម សរសេរ តាម តែប្រជាជន នោះ ទេ ដែល ជា អ្នក ប្រើ ភាសា ។ កាល ណា ប្រជាជន មិន ប្រើ ប្រាសតាម, បាន សេចក្តី ថា ពាក្យ ទាំង នោះ គឺ ដេក ស្ងៀម ក្នុង ក្បួន ព្រោះ ជា វេយ្យករណ៍ធម្មនិយាម (grammaire normative) ដែល គេ មិន អាចអនុវត្ត តាម បាន ។ ហេតុនេះសូម អស់ លោកភាសាវិទូខ្មែរ យើងគួរ តែពិនិត្យ ពិចារណា ឲ្យ បាន គ្រប់ គ្រាន់

[9]"Adhémar Leclère - Texte cambodgien du récit d'un nommé Meas qui raconte à ses compatriotes ce qu'il a vu et qui dit ce qui était le pays avant le proclamation du protectorat français sur le Cambodge et les avantages pour le pays que procure le régime nouveau - répandu à 10.000 exemplaires".

[10]*វចនានុក្រម ខ្មែរ, Dictionnaire cambodgien*, ភាគ១, ក-ម, ភ្នំពេញ, ១៩៣៨; ភាគ២, យ-អ, ភ្នំពេញ, ១៩៤៣; បោះពុម្ពឡើងវិញ, ភាគ១, ១៩៦៧; ភាគ២, ១៩៦៨ ។

[11]សូម អាន *វចនានុក្រម ខ្មែរ*បោះពុម្ពដំបូងនាឆ្នាំ១៩៣៨-១៩៤៣ ។



ជ្រៅជ្រះជាមុនសិនមុននិង បង្ខំឲ្យ ប្រជាជន អនុវត្តតាម ភ្លាមៗ ពោល គួរ តែ ធ្វើជាវេយ្យករណ៍ពិពណ៌នា សិនជាដំណាក់កាលដំបូង ។

ការបោះពុម្ព ឡើង វិញ នៃ «រឿងបណ្តាំ តា មាស» នេះ មាន អត្ថបទ ជាអក្ខរាវិរុទ្ធ ទំនើប តាម វចនានុក្រម ផ្លូវ ការ និង អត្ថបទ ថត តាម អក្ខរាវិរុទ្ធ ដើមរបស់ ឯកសារ ដោយ មាន គោល បំណង បង្ហាញ ការវិវត្តន៍ នៃ ភាសា យើង ពី ដើមសតវត្សទី២០រហូតមកដល់ បច្ចុប្បន្នកាល នេះ ។ អត្ថបទនេះទៀតសោតមានប្រយោជន៍ដល់ អ្នកសិក្សាប្រវត្តិសាស្ត្រនិងជនានុជន យើងឲ្យដឹងពីស្ថានភាពស្រុកទេសកម្ពុជាពីសតវត្សទី១៩រហូតមកដល់ឆ្នាំ១៩០៨ ។

យើង សង្ឃឹម ថា ស្នា ដៃ «តាមាស »នេះ នឹង ជួយ ពង្រីក ពង្រឹង ស្មារតីប្រជាជនខ្មែរកុំឲ្យភ្លេចខ្លួននិងបង្រស់ពង្រឹងព្រលឹងខ្មែរ គ្រប់ៗ គ្នា ។

សូមសិរីសួស្តីដល់កវីនិពន្ធខ្មែរទួទៅ

សាស្ត្រាចារ្យបណ្ឌិតឃីងហុកឌី

# បណ្ដាំតាមាស

(អត្ថបទ កែ តាមអក្ខរាវិរុទ្ធ វចនានុក្រម ផ្លូវ ការ)

# រឿងបណ្តាំតាមាស

នាមខ្ញុំឈ្មោះមាស ជាចាស់ព្រឹទ្ធាចារ្យអាយុជាង៨០ឆ្នាំហួយ កើតក្នុងឆ្នាំជូតសំរិទ្ធិស័កចុល្លសករាជ១១៩០បើគិតជាសករាជបារាំងត្រូវថែម លេខ១ទៀតទើបត្រូវនឹងឆ្នាំ១៨២៨តែងជាពាក្យបណ្តាំនេះទុកឲ្យកូនចៅនៅឯក្រោយចួលចាំគ្រប់គ្នានិយាយប្រាប់គ្នាតៗ ទៅ។

កាល ដើមឡើយ ឪពុកខ្ញុំធ្វើជាបាឡាត់ខែត្រលង្វែកជាខែត្រកាលនោះជីតាខ្ញុំធ្វើជាចៅហ្វាយ ស្រុកនោះខ្ញុំទាន់ជីតាខ្ញុំគាត់ច្បាំងនិងយួនកាលរាជ្យហ្លួងអង្គម៉ី ហើយ គាត់បាត់បង់ក្នុងទ័ព តមកទៀតឪពុកខ្ញុំគាត់នាំកងទ័ពទៅដេញយួនៗ ក៏បាត់រត់ខ្ចាត់ខ្ចាយទៅគ្រប់ទិសឯខ្លួនគាត់ក្តីបាត់មិនដឹងជាទៅឯណាមិនឃើញគាត់ត្រឡប់មកផ្ទះវិញជីដូនខ្ញុំគាត់បាត់បង់ជាង១១ឆ្នាំ ១២ឆ្នាំមុនជីតាខ្ញុំនៅកណ្តាលផ្លូវដែលទៅពីបាត់ដំបងទៅបាងកកដ្បិតកាលនោះពួកកងទ័ពសៀមកៀរគាត់នាំទៅជាឈ្លើយឯម្តាយខ្ញុំគាត់បាត់បង់នៅវេលាដែលយួនលើកមកលុកប្លន់បន្ទាយលង្វែកបងប្អូនប្រុសខ្ញុំ៣នាក់អនិច្ចកម្មក្នុងទីចម្បាំងកាលនោះទៅច្បាំងជាមួយនឹងមាគាត់២នាក់ហើយ និងបងប្អូនជីដូនមួយច្រើននាក់ដែរនាំពួកកងទ័ពស្រុះចិត្តគ្នាទៅច្បាំងឯខ្លួនខ្ញុំចូលច្បាំងនឹងគេបាន៣ឆ្នាំដរាបទាល់តែស្រុកសាន្តត្រាណ ហើយ ហ្លួងអង្គឌួងចុះសន្យាធ្វើស្ពានមេត្រីនឹងសៀមនឹងយួន។

វេលានោះខ្ញុំក៏ធំមានអាយុក្រែលល្មមឃើញស្គាល់ចាំការគ្រប់ជំពូកបានហើយបានយល់ច្បាស់ដែរពួកនាម៉ឺនៗ គេនិយាយគ្នានៅប្របខ្ញុំៗ ចាំបានទាំងអស់។

ស្រុកកាលនោះបាក់បែកក្រទ័លក្នុងមួយភូមិៗរកប្រាក់មួយរៀលគ្មាន រត់ចោលស្រែចំការច្បារដំណាំខានដាំភ្នូររាស់ស្លូងព្រួសសាប ព្រោះខ្លាចយួនសៀមវាមកកំហែងច្រូតយកស្រូវក្នុងស្រែ ដើមដូងស្លានិងដើមឈើស៊ីផ្លែទាំងប៉ុន្មានកាប់ចោលជាងពាក់កណ្ដាល ហើយក្នុងភូមិដែលជីតាដែលឪពុកខ្ញុំគាត់ធ្លាប់ឃើញស្គាល់ពីដើម មានផ្ទះ ១៤០ នោះឃើញនៅតែផ្ទះ ៦០ ផ្ទះ ៤០ ផ្ទះ ២៤ វិញ ៚ រាស្ត្រចំណុះស្រុកក៏តិចជាងពីដើម ពួកសមណៈជីព្រាហ្មណ៍ក៏កើតទុក្ខវេទនា ព្រោះវាលុកប្លន់ព្រះវិហារអារាម ជញ្ជូនយកព្រះពុទ្ធរូបណាដែលជាមាសជាប្រាក់ជាសំរិទ្ធិ ហើយវាដុតព្រះវិហារវត្តអារាមជាច្រើន អន្លើវត្តណាដែលនៅសល់ នោះរកដំបូលគ្មានដំបូល នោះស្រុតបាក់ធ្លាក់ទៅគ្របលើអាសនៈព្រះ រកនរណានឹងមានចិត្តគិតជួសជុលគ្មាន ព្រោះរវល់តែនឹងច្បាំងរាំងជល់រៀងមកជាប់ ៤០ ឆ្នាំ ស្រុកភូមិបាក់បែករត់ចោលស្ងាត់សូន្យឈឹង មុខគួរឲ្យស្រងេះស្រងោចខ្លោចផ្សាណាស់ណា វេទនានឹងស្រីដែលមានកូនតូចៗ អង្គុយឱបក្បាលជង្គង់មុខច្រមិសមើលតែមុខកូនភ្លឺះៗ ។

លុះបានស្រុកសាន្តត្រាណបាន ចុះសន្យាជាស្ពានមេត្រី នោះហ្លួងអង្គឌួងបានសោយរាជ្យជាស្ដេចហើយ នោះរាស្ត្ររាល់គ្នាគ្រាន់មានចិត្តសង្ឃឹម ហើយគេនិយាយសរសើរថា ស្ដេចល្អ ទ្រង់ធម៌ ព្រះទ័យសប្បុរស ជ្រះថ្លា ដឹងអធ្យោគអធ្យាស្រ័យ ប៉ុន្តែស្រុកយើងកាលនោះខ្សត់ណាស់ អស់អាណាប្រជានុរាស្ត្រលំបាកក្រពេកពន់ប្រមាណ ចេះតែនៅទ្រាំចាំសៀមពុំបានរកស៊ីអ្វីសោះ ។

៚ ខ្លួនខ្ញុំកាលនោះក៏ក្រណាស់ ហើយគ្មានញាតិផៅសាច់សន្តានព្រៀងលានសោះ ៚ ចំណេះវិជ្ជាការក៏ឱនថយ ស្គាល់តែសេចក្ដីទុក្ខវេទនា ក៏មានចិត្តកាត់តម្លាសទ្ធាចង់បួស ស្រេចហើយក៏ចូលឧបសម្បទ័ក្នុងសំណាក់ព្រះពុទ្ធសាសនា នៅក្នុងអារាម ១ ក្នុងក្រុងឧដុង្គមានជ័យ ដើម្បីនឹងបានមគ្គផលទៅជាតិក្រោយ កុំឲ្យអកុសលដូចជាតិនេះ ហើយនិងបានរៀនសូត្រធម៌អាថ៌សត្រាបាលីផង រួចចុះថែមទាំងអកុសល ៚ ក្នុងវត្តសោតក៏រករៀនធម៌អាថ៌សត្រាបាលីគ្មាន ភ្លើងឆេះ



ខូចអន្តរាយខ្លះ សៀមវាលួចយកខ្លះ យួនវាបំផ្លាញខូចខ្លះ ៚ ក្នុងវត្តប្រាង្គដែលខ្ញុំបួសភិក្ខុនោះសោតក៏មាននៅសល់តែលោកសង្ឃល្ងង់ខ្លៅ ពុំមានគិតរកសត្រាវិន័យនិងគម្ពីរព្រះអភិធម្មព្រះត្រៃបិដកឡើយ ។

៚ កើតច្បាំងក្នុងស្រុកខ្មែរហើយ ចុះសន្យាធ្វើស្ពានមេត្រីរួចហើយ នោះពួកមហាសត្រូវយើងទាំងសងខាងគឺស្ដេចសៀមហើយនិងស្ដេចយួនវានៅតែក្ជួនយកដីយើងទៀត ៚ ស្ដេចសៀមយកខែត្រចំណែកខាងជើង គឺស្រុកសៀមរាប មាននគរធំក្រុងស្រុកខ្មែរយើង ហើយស្រុកបាត់ដំបងម្លូព្រៃទន្លេរពៅ ហើយនិងខែត្រយើងខ្មែរទាំងប៉ុន្មានដែលនៅមាត់សមុទ្រខាងទិសបស្ចិម ៚ ស្ដេចយួនយកដីដែនស្រុកខ្មែរទាំងប៉ុន្មាននៅខាងត្បូង គឺព្រៃនគរ កូសាំងស៊ីនសព្វថ្ងៃនេះ រហូតទៅដល់ទល់នឹងព្រែកជីកខែត្រពាមខាង ៚ លិច ខាង ៚ កើត យករហូតទៅទន្ទឹមនឹងក្រុងភ្នំពេញ ។ ៚ ស្ដេចម្ចាស់ផែនដីយើងលោកកើតទុក្ខព្រួយព្រះទ័យដូចជារាស្ត្រដែរ ព្រោះទ្រង់ឈ្វេងយល់ថា សៀមហើយនិងយួនវាគិតយកស្រុកខ្មែរបញ្ចូលក្នុងស្រុកវារាល់គ្នា ប៉ុន្តែវាបញ្ចូលមិនទាន់បាន ព្រោះវាជាសត្រូវនឹងគ្នា ហើយចែកគ្នាមិនកើត ដ្បិតវាចង់បានតែទាំងអស់រាល់ខ្លួន ។ ម្ចាស់យើងលោកព្រួយព្រះទ័យ ១ ជំពូកទៀត ព្រោះសៀមវាចង់ទំនុកបំរុងលោកៗពុំសព្វព្រះទ័យ ព្រោះវាមិនទុកលោកជាស្ដេចផែនដីស្រុកខ្មែរ វាទុកលោកដូចជាចៅហ្វាយស្រុកខ្មែរវិញ ៚ យួនវាទុកលោកជាចំណុះវា ហេតុដូច្នេះព្រះអង្គក៏រឹតតែព្រួយព្រះរាជហឫទ័យ ក្រែងកើតចម្បាំងជាថ្មីទៀត ក្រែងស្រុកខ្មែរនឹងវិនាសអន្តរាយ ហើយផុតមានអស់ពូជខ្មែរ ក្រែងនៅតែសៀម ឬនៅតែខ្មែរដែលទុកសក់ប្អូងពីក្រោយ ដូចជាពួងស្លៀងយកកន្សែងជូតក្បាល ដូចជាយួន ។

៚ ហ្លួងយើងកាលនោះលោកចេះតែខំប្រឹងតាមការ ទ្រង់ចាត់ឲ្យចម្លងសត្រាបាលីច្បាប់ទម្លាប់ ហើយស៊ើបសួររកពង្សាវតារដែលនៅសល់ឃើញទាំងប៉ុន្មាន ឲ្យយកមកចម្លងទុក ព្រោះលោកមានព្រះរាជហឫទ័យដើម្បីនឹងរៀបចំ

ស្រុកខ្មែរយើងឲ្យរបបរៀបរយតែទ្រង់នៅមានព្រះរិតក្កក្រែងតទៅមុខសៀម ហើយនិងយួនវាយកស្រុកយើងខ្មែរចែកគ្នា ទ្រង់ព្រះចិន្តាតែម្ល៉ោះ ទើបទ្រង់ឈ្វេងយល់ថានឹងពឹងស្រុកយូរ៉ុប[1] ណា១ឲ្យជួយទំនុកបំរុងឥឡូវនឹងពឹងបុណ្យអាំងក្លេស[2] បានស្រុកក្លឹង[3] ហើយនិងស្រុកសឹង្គះបួរ[4] ហើយឥឡូវនឹងទៅពឹងបុណ្យវិឡាន្ដា[5] ទ្រង់ពុំសព្វព្រះទ័យ ដ្បិតវិឡាន្ដាធ្វើជាចៅហ្វាយនៅស្រុកយ៉ាវ៉ា[6] ស្រុកសូម៉ាត្រា[7] ហើយឥឡូវនឹងទៅពឹងបុណ្យអឺះស្ប៉ាញ៉ុល[8] ឬប្រូតូកេស[9] ដ្បិតសាសន៍ទាំងនោះពុំពូកែ ទ្រង់ព្រះចិន្តាតែម្ល៉ោះស្រេចហើយក៏ទ្រង់សម្រេចថានឹងពឹងបារាំងសែស ដ្បិតបារាំងសែសគ្មានស្រុកចំណុះនៅប្រែបស្រុកខ្មែរ ។

១ទៀតកាលពីដើមទ្រង់គង់នៅស្រុកបាងកកបានជួបនឹងបារាំងសែស ហើយទ្រង់ទតយល់រីករាយ មិនឆ្មើងកន្ត្រើងនឹងនរណារាក់ទាក់រាប់អានអ្នកទាំងពួង ហើយចិត្តថ្លើមក៏មានធម៌សប្បុរស ទើបទ្រង់សម្រេចថាសុំពឹងបារាំងសែសឲ្យជួយទំនុកបំរុងការព្រះរាជសត្រូវយួននៅស្រុកព្រៃនគរ ហើយនិងការព្រះរាជសត្រូវសៀមជាដើម ព្រោះមានខា[10] លួងមកឈរអមព្រះអង្គនៅស្រុកឧដុង្គមានជ័យ ទ្រង់មានព្រះទ័យអៀនខ្មាស ចង់ឲ្យរបូតរួចពីដៃសៀមនោះ

[1] ស្រុកអឺរ៉ុប (យូរ៉ុបគឺយើងអានតាមសៀមឬតាមអង់គ្លេស)

[2] Anglais (Angleterre)

[3] Inde. ឥណ្ឌា

[4] Singapour. សិង្ហបុរី

[5] វិឡាន្ដាឬវិឡាន្ដាក្នុងភាសាខ្មែរសម័យកណ្ដាលយើងសំដៅស្រុកហុលលង់ (Hollande, Hollandais)-.

[6] Java ឬ ស្រុកជ្វា ។

[7] Sumatra

[8] Espagnol

[9] Portugais.

[10] ពាក្យសៀមមានន័យថា «ខ្ញុំ, បម្រើ» ។



ណាស់ ទើបទ្រង់តែងរាជទូត២នាយឲ្យនាំព្រះរាជសារទៅដល់កុងស៊ុល[11] បារាំងសែសនៅស្រុកសឹង្គះបួរ១ច្បាប់ ទៀតទៅដល់អំម្ប៊ឺរ៉ឺរ[12] ស្ដេចបារាំងសែសក្នុងសេចក្ដីព្រះរាជសារនោះ ថាសុំពឹងបុណ្យស្ដេចបារាំងសែស សុំឲ្យស្ដេចបារាំងសែសតែងរាជទូតចូលមកនឹងចុះសន្យាគ្នា នោះស្ដេចបារាំងសែសមិនឃើញតែងរាជទូតឲ្យមកចុះសន្យា ស្រាប់តែចាត់កងទ័ពមកច្បាំងនឹងស្ដេចទេព្វាស្រុកយួន ហើយវាយយកស្រុកព្រៃនគរ ហើយយកស្រុកកូសាំងស៊ីនបានពាក់កណ្ដាលជាមុន ទើបយកពាក់កណ្ដាលទៀតរៀងទៅទល់នឹងខែត្រពាមនោះ ហ្លួងក៏មានព្រះរាជហឫទ័យអំណរ ដោយសារឃើញបារាំងសែសលើកទ័ពមកវាយដេញយួនកាលហ្លួងសុគតក្នុងឆ្នាំមមែឯកស័កចុល្លសករាជ១២២០ឆ្នាំ ។

គិតរំពឹកឃើញពីដំណើរទាំងនោះសព្វគ្រប់ ទៅខ្ញុំមានចិត្តអំណរនឹងបារាំងសែសដែលមកដេញយួនវាជាសត្រូវនឹងយើងខ្មែរ វាវាយដណ្ដើមសង្កត់សង្កិនស្រុកយើងជិតៗ តែនឹង ៣០ ឆ្នាំហើយ វាតាំងស្ដេចស្រីៗ បីព្រះអង្គជាឯករាជ១អង្គជាទីឧបរាជ១អង្គទៀតជាទីព្រះកែវហ្វា ហើយវាធ្វើបន្ទាយវាយពេញតែស្រុកខ្មែរ ចិញ្ចឹមខ្មែរឲ្យធ្វើចៅហ្វាយស្រុកឲ្យទុកសក់ស្លៀកពាក់តាមសាសន៍វាជាយួន ហើយវាគិតផ្លាស់ឈ្មោះខែត្រស្រុកខ្មែរដាក់ឈ្មោះជាយួន ប៉ុន្តែនៅវេលានោះយើងខ្លាចតែបារាំងសែសកាលណាវាយស្រុកយួនរួចហើយក៏ត្រឡប់ទៅស្រុកវិញមិនមកជួយយើងខ្មែរ ។

៦ បារាំងសែសដែលលើកទ័ពទៅច្បាំងនឹងស្ដេចយួននោះ បើអ្នកទាំងឡាយពុំដឹងជាហេតុដើមទងដូចម្ដេចនោះខ្ញុំនឹងអធិប្បាយរាយដំណើរជូនស្ដាប់តាមដែរខ្ញុំបានដឹងឮគេនិយាយរាល់គ្នានៅវេលាគ្រានោះ ថាកាលនោះប្រហែលជាង១២០ឆ្នាំមកហើយ នោះកូនស្ដេចស្រុកយួនច្បាំងនឹងពួកក្បត់ដែលគិតបះ

[11] Consul គឺជាបុគ្គលិកទូតមានឋានន្តរសក្តិខ្ពស់ជិតស្មើរាជទូត ។

[12] Empereur គឺជាស្ដេចចក្រភព ។

ច្យាំងដណ្តើមយករាជស្រុកយួនក៏កាលនោះ មានពួកសេនាទាហានបារាំងសែស ហើយនិងពួកកប៉ាល់ចម្បាំងទាំងអស់ជាង៤០០នាក់ចូលចិត្តយកអាសារធ្វើរាជការថ្វាយ ហើយច្យាំងនឹងពួកក្បត់នោះយករាជ្យថ្វាយ ឯពួកបារាំងសែស ដែលប្រដៅសាសនាគ្រិះស្តាំង[13] ទៅអន្ទងយកពួកសេនាទាហានទាំងនោះមកជួយស្តេចស្រុកយួនព្រោះតែពួកប្រដៅសាសនាទាំងនោះមានចិត្តស្លូតត្រង់នឹងស្តេចយួនធ្វើរាជការថ្វាយស្តេច ហើយអស់អាណាប្រជានុរាស្ត្រយួនក៏ស្រឡាញ់រាប់អានពួកប្រដៅសាសនាទាំងនោះណាស់ ហើយមានរាស្ត្រយួនប្រុសស្រីជាច្រើនលែងចោលសាសន៍របស់ខ្លួនរត់ចូលសាសន៍បារាំងសែស ។

ឯពួកសេនាទាហាននិងពួកបារាំងសែសទាំងប៉ុន្មានដែលពួកប្រដៅសាសនាបង្គាប់បញ្ជានោះក៏មានចិត្តក្លាហាន ហើយនាំពួកកងទ័ពស្តេចយួនច្យាំងនិងពួកក្បត់ៗ ក៏អបរាជ័យ[14]ចាញ់បាក់បបខ្លបខ្លាចហើយ អ្នកស្តេចទេព្ភាយ៉ាឡុងក៏បានឡើងសោយរាជ្យជាស្តេចគ្រប់គ្រងមិនតែក្នុងចំណែកនគរយួនហើយ និងស្រុកកូសាំងស៊ីនឡើយ ទាំងស្រុកតុងកឹងក៏បានចូលមកក្នុងព្រះរាជាណាចក្រទាំងអស់ ឯនគរស្តេចយួនក៏បានធំទូលាយឡើងខាងជើងរហូតហួសស្រុកចិនទៀតទៅទល់នឹងសមុទ្រខាងកើតដែលគេហៅសមុទ្រសៀមពីខាងទិសនីរតីទល់នឹងខែត្រពាម ឯនគរយួនកាលនោះចម្រើនធំទូលាយជាធម្មតា ។

រីស្តេចយ៉ាឡុងជាស្តេចយួន នោះស្លាប់ក្នុងឆ្នាំថោះឯកស័ក សករាជ ១១៨១ឆ្នាំមានកូនប្រុស១ឈ្មោះមិញម៉ាងឡើងសោយរាជ្យតវង្សឈ្មោះស្តេច

---

[13]Christian (អានតាមសំនៀងអង់គ្លេស) ។

[14]«អបរាជ័យ»ក្នុងអត្ថបទនេះមានន័យថា«បរាជ័យ, ចាញ់...» ។ ទម្លាប់ខ្មែរសម័យកណ្តាលប្រើផ្ទុយពីន័យក្នុងភាសាបាលី ។ «អបរាជ័យ»គឺមានន័យប្រាកដគឺ«មិនចាញ់» ។



មិញម៉ាងនោះឯងដែលចាត់កងទ័ពយួនឲ្យមកច្យាំងនឹងយើងខ្មែរ កាលនោះជាចម្បាំងធំណាស់នគរយើងខ្មែរនេះហៀបតែនឹងបានដៃយួន ។

ឯស្តេចយួននោះជាមនុស្សកំណាចច្រណែននិន្ទាឈ្នានិសចេះតែរអៀសខ្លួនមិនទុកចិត្តនរណាហើយតាំងធ្វើទុក្ខបុកម្នេញពួកសេនាទាហានបារាំងចំនួន ១២នាក់ដែលចូលមកនៅៗ ធន់មិនបានស្លាប់អស់សល់តែ២នាក់ក៏ធន់មិនបានហើយនាំប្រពន្ធយួនហើយនិងកូនដែលកើតពីប្រពន្ធយួននោះត្រឡប់វិលទៅស្រុកបារាំងវិញ ។

កាលក្រោយពួកបារាំងសែសចេញទៅនោះ ស្តេចយួនតាំងតែសង្កត់សង្កិនធ្វើបាបពួកលោកសង្ឃបារាំង ហើយនិងពួកយួនដែលចូលសាសន៍គ្រិះស្តាំងហើយឲ្យចាប់ចងក្រពើធ្វើបាបនិងប្រហារជីវិតលោកសង្ឃបារាំងសែសហើយនិងពួកចូលសាសន៍នៅក្នុងស្រុកយួនស្រុកតុងកឹងស្រុកកូសាំងស៊ីនជាច្រើន ។

ស្តេចនគរបារាំងសែសបាននិយាយរំឭកទូន្មានជាច្រើនដងច្រើនគ្រាប៉ុន្តែស្តេចយួនមិនទទួលស្តាប់យកចិត្តទុកដាក់សោះចេះតែរឹតធ្វើបាបពួកប្រដៅសាសនាហើយនិងពួកចូលសាសន៍តទៅមិនតែប៉ុន្តែម្ល៉ោះសោត ស្តេចយួននៅរឹងទទឹងមិនទទួលឲ្យជួបសំដីនឹងរាជទូតនគរបារាំងសែស ហើយមិនព្រមទទួលមើលស្តាប់ព្រះរាជសារដែលស្តេចនគរបារាំងសែសឲ្យរាជទូតនាំមកនោះផង ។

ឯស្តេចយួនឈ្មោះមិញម៉ាងនោះស្លាប់ប្រហែលក្នុងឆ្នាំដែលហ្លួងម្ចាស់អង្គឌួងយើងបានឡើងសោយរាជសម្បត្តិគ្រប់គ្រងក្រុងកម្ពុជាធិបតី ហើយនៅវេលាគ្រានោះគេចេះតែក្រែងថាស្តេចស្រុកបារាំងសែសនិងចាត់កងទ័ពឲ្យមកផ្តន្ទាអស់ពួកយួនដែលរាប្រព្រឹត្តបទអាក្រក់ខុសនឹងធម៌ ។

លុះដល់ស្តេចធៀវទ្រីបានឡើងសោយរាជ្យក្នុងស្រុកយួននោះឃើញអន់កំណាចនឹងពួកប្រដៅសាសនាគ្រិះស្តាំង ហើយបានបើកពួកប្រដៅ

សាសនាដែល ខ្មោចស្តេចឪពុកចាប់ដាក់គុកទាំង ប៉ុន្មានៗ នោះ ប្រគល់ ខ្លួន ឲ្យ កុំម៉ង់ឡាំង[15] នាយ កប៉ាល់ ចម្បាំង បារាំង សែស ទាំង អស់ ប៉ុន្តែ អំណើះ តមក ក្រោយ ទៀត ស្តេចធៀវទ្រីក៏តាំងឲ្យធ្វើបាបសង្កត់សង្កិនទៀត ហើយ បង្គាប់ ឲ្យយកទោសដល់ជីវិតឥតជំនុំជំរះ ពួកបារាំងទាំងប៉ុន្មាន ដែល ប្រទះ ឃើញ នៅក្នុងស្រុក យួន ឃើញ ស្តេច យួន ប្រព្រឹត្ត បទ ឥតសប្បុរស ដូច្នោះ នោះ រាជការ ក្រុង បារាំង សែស ក៏យល់ ថានឹង ធន់ អត់ទ្រាំឲ្យ ស្តេចយួន ប្រព្រឹត្តដូច្នោះតអង្វែង ទៅទៀតមិនបាន លុះគិត ស្រេច ដូច្នោះក៏ ចាត់កប៉ាល់ ចម្បាំង ២ មក បាញ់ បន្តក់គ្រាប់បែកលើស្រុកទូរ៉ាន ឆេះផ្ទះសម្បែងអ្នកស្រុកទាំងប៉ុន្មានអស់ ៦ អ្នក ស្តេច ធៀវទ្រី កើត ទុក្ខ អន់ ចិត្ត ហើយ ភ័យ បារម្ភ ជា ខ្លាំង ក៏ អស់ បុណ្យ ទទួល អនិច្ចកម្ម ហើយ មានកូនប្រុស នាម ឈ្មោះ ទឺឌិគ ឡើង គ្រង រាជសម្បត្តិ ជា តំណ ស្តេចឪពុកក្នុង ចុល្លសករាជ១២០៩ ឆ្នាំមមែនព្វស័កនៅវេលានោះ សេចក្តីដែល ប្រព្រឹត្តជាបឋមកម្ម គឺសង្កត់សង្កិនកំហែង កំចោករោកពួក បារាំង ក៏រឹងរឹត តែខ្លាំងឡើងនឹងគិតគណនាពុំបានឡើយ ។

លុះដល់ ១០ ឆ្នាំ ត មក ទៀត នោះ រាជការ ស្រុក បារាំង សែស ហើយ និង រាជការ ស្រុក អាំងគ្លេស និង ធន់ អត់ ទ្រាំ ពុំ បាន ក៏ ចាត់ កង ទ័ព ស្រុក ទាំង ២ ជិះ កប៉ាល់ ភ្លើងមកធ្វើទោស ផ្តន្ទាអស់ពួកចិនដែលវាប្រព្រឹត្តបទអធម៌ រួចយួនវាធ្វើ បាប ហើយ ចេះតែប្រមាថមាក់ងាយពួកបារាំង ហើយ និង ពួក បារាំង អ្នកដើរសមុទ្រនោះកងទ័ពនគរ ទាំង ២ ចូល លុក វាយ ស្រុក ក្រុង ស្តេច ក្រុង ចិន ប្រាប់ចិនទាំងអស់ទាំងនគរឲ្យដឹងខុសដឹងត្រូវ ។

លុះបានធ្វើទោសផ្តន្ទាស្រុកចិនរួចហើយ ពួកកងទ័ពអាំងគ្លេសក៏ ត្រឡប់វិល ទៅស្រុកវិញ នៅតែ បារាំង សែស ដែល កាល មុន នោះ បាន ធ្វើ ទោស ផ្តន្ទាអស់ពួកយួនក៏ឈប់នៅស្រុក អាំងដូស៊ីន វាយស្រុកទូរ៉ាន់ ក្នុង ឆ្នាំ មមី

[15] Commandant នាយ ទាហាន សក្តិ ៤ ។



សំរិទ្ធិស័កយកស្រុកព្រៃនគរក្នុងឆ្នាំមមែឯកស័ក ហើយ វាយ យក បាន អស់ទាំងស្រុកកូសាំងស៊ីនក្នុង២ឆ្នាំ៣ឆ្នាំ តមកក្រោយទៀតនេះព្រោះតែ ហេតុដូច្នេះបានជាបារាំងសែស ច្បាំងនឹងស្តេចយួន ។

១ទៀតហេតុដូចម្តេចបានជា ស្រុក ខ្មែរ យើងក៏ លែងភ័យ បារម្ភនឹងយួន រួចហេតុដូចម្តេចក៏បានជានៅតែសត្រូវ១ចំណែកគឺសត្រូវនឹង ស្តេច សៀម នោះ កាលនោះ ព្រះបាទ សម្តេច ព្រះនរោត្តម ជា ព្រះរាជបុត្រា ថ្លៃ នៃ ព្រះបាទ សម្តេច ព្រះហរិរក្សរាមា ឥស្សរាធិបតី (ព្រះអង្គឌួង) ដែល ពាក្យ រាស្ត្រ ទាំង ពួង ហៅ ថា ហ្លួង សុវណ្ណកោដ្ឋបានឡើងសោយរាជ្យសម្បត្តិ គ្រង ក្រុង កម្ពុជា ខ្មែរ យើង ក្នុង ចុល្លសករាជ១២២០ឆ្នាំមមែឯកស័កនោះទ្រង់មានព្រះរាជហឫទ័យ បារម្ភក្រែង តែស្រុកបារាំងសែស មិនមកជួយ ទំនុកបំរុងក្រុងកម្ពុជា នោះ ស្តេច សៀម នឹង សង្កត់យកក្រុងកម្ពុជារួចពីនោះមកទៀតនៅមាន ព្រះអង្គម្ចាស់ស៊ីវត្ថាដែល ជា ព្រះរាជបុត្រទី៣នៃព្រះបាទសម្តេចហរិរក្សរាមា ដែល មិនគួរគប្បីនឹង ត្រូវឡើង គ្រងរាជសម្បត្តិដំណាង អង្គសម្តេចព្រះវររាជ បិតា នោះគិត បះបោរ តាំង ជា កង ទ័ព ហើយរត់ទៅជ្រកក្នុងស្រុកសៀម ។

៦ស្តេចស្រុកសៀមបន់ឲ្យតែម្ចាស់ស៊ីវត្ថា លើកកង ទ័ព ចូល មក ច្បាំងនឹង ព្រះបាទសម្តេច ព្រះនរោត្តម ក្នុងកម្ពុជាវិញដូចកាល ដែល ព្រះរាជវង្សា ខ្មែរទាំងប៉ុន្មានដែលក្បត់តាំងតែអំពីដើមរៀងមក នោះតែរត់ទៅ ជ្រកពឹង បុណ្យសៀមៗ តែងតែជួយកាន់ជើងរៀងរៀបដរាបមក ។

នោះនៅវេលានោះក្នុង ស្រុកខ្មែរក៏តាំងមាន សឹកសង្គ្រាម ច្បាំងរាំងជល់ ឡើងវិញ មិនតែច្បាំងពីព្រោះព្រះអង្គស៊ីវត្ថានោះឡើយ នៅ មាន ពួក ក្បត់តាំងខ្លួនជាអាចារ្យ អាក្បត់១នោះឈ្មោះអាស្វា វា បំបះ ខាង ខែត្រទ្រាំងបន្ទាយមាសពាមហើយលើកកងទ័ព លុក វាយ យក ស្រុក កំពត អា១ទៀតឈ្មោះពោកំបោរ វា បំបះខាង ខែត្រ ក្រចេះ ស្លូង ត្បូង ឃ្មុំ បាភ្នំ ។

ឯអាក្បត់ទាំងពីរនាក់នោះ កាលកងទ័ពហ្លួងដេញប្រកិតជិតនឹងចាប់បានខ្លួនវាៗ រត់ទៅចូលក្នុងដែនស្រុកកូសាំងស៊ីនពួនក្នុងស្រុកពាមមាត់ជ្រូកលង់ហោរដែលនៅក្នុងអំណាចយួនៗ វាទំនុកបំរុងអាក្បត់ទាំងពីរនោះ ព្រោះយួនវាជាមហាសត្រូវនឹងខ្មែរយើងពីដើមមកស្រេចហើយ អាក្បត់ទាំងពីរនោះវាត្រឡប់ចូលមកដើររាតត្បាតបំបះបំបោរអស់រាស្ត្រប្រជាក្នុងស្រុកខ្មែរទៀត ។

នៅរដូវដើមឆ្នាំ ចុល្លសករាជ១២២២ ឆ្នាំរកាទោស័ក ចៅហ្វាយស្រុកបារាំងសែសនៅស្រុកព្រៃនគរដែលបង្គាប់លើកងទ័ពជើងគោកជើងទឹកទាំងប៉ុន្មាន ចាត់នាម៉ឺនបារាំងសែស ១ នាក់ ជិះកុប៉ាល់មកចតនៅខែត្រកំពតស្រេចឡើងទៅថ្វាយបង្គំគាល់ព្រះបាទសម្ដេចព្រះនរោត្តមកាលទ្រង់គង់នៅព្រះបរមរាជវាំងឧដុង្គមានជ័យហើយ យកសេចក្ដីក្រាបបង្គំទូលតាមផ្លូវរាជការថារាជការបារាំងសែសគិតសម្រេចថា ត្រូវយកស្រុកកូសាំងស៊ីនទុកជារបស់រាជការបារាំងសែស ព្រះបាទសម្ដេចព្រះនរោត្តមបានទ្រង់ជ្រាបដូច្នេះក៏មានព្រះរាជហឫទ័យសោមនស្សនឹងរាជការបារាំងសែស យកស្រុកកូសាំងស៊ីនផ្ដាច់ជារបស់បារាំងសែស លុះវិលងបាន ១ ខែតមកនោះ ព្រះបាទសម្ដេចនរោត្តមទ្រង់តែងរាជទូតឲ្យទៅជួយអំណរចៅហ្វាយស្រុកបារាំងសែសនៅស្រុកព្រៃនគរ ឯសៀមកាលឃើញព្រះបាទសម្ដេចព្រះនរោត្តមព្រមទទួលស្រុះស្រួលនឹងបារាំងសែសក៏អន់ចិត្តដ្បិតបារាំងសែសខ្លាំងពូកែជាងខ្លួនហើយ បានមកទំនុកបំរុងក្រុងកម្ពុជា ស្រេចហើយធ្វើសំបុត្រសន្យា បន្លយយួនហើយនិងសៀមពីស្រុកខ្មែរ ដាក់ស្រុកខ្មែរឲ្យនៅក្នុងទំនុកបំរុងរាជការបារាំងសែសដែលជាមហានគរធំវិញហើយ ហាមប្រាមនគរសៀមនគរយួនកុំឲ្យលើកទ័ពមកដណ្ដើមយកក្រុងកម្ពុជាតទៅ ។

តាំងពីបានរាជការបារាំងសែសមកទំនុកបំរុងកាលណា ក្រុងកម្ពុជាក៏បានសម្បូណ៌សោភិនី ឥតមានសត្រូវឯណាមកបៀតបៀនយាយីហើយ



អាណាប្រជានុរាស្ត្រក៏រកស៊ីសុខសប្បាយតាមដោយសុចរិតពិតត្រង់ ពុំមានព្រួយនឿយភិតភ័យរត់លូននឹងសឹកសមរ[16]សង្គ្រាមជ័យឡើយ ។

កាលនោះ បារាំងសែសបានធ្វើរាជការថ្វាយសម្ដេចព្រះនរោត្តមជួយច្បាំងដេញចាប់អាចារ្យស្វា ពោកំបោរ ឯខ្លួនពោកំបោរបាក់ទ័ពពីក្នុងខែត្របាភ្នំ រត់ទៅដល់ស្រុកកំពង់ធំខែត្រកំពង់ស្វាយ ចាប់បានហើយប្រហារជីវិតនៅទីនោះ ។

នៅវេលានោះក្នុងទន្លេសាប ទន្លេធំហើយនិងតាមដងស្ទឹង មានតែទូកថ្ងៃចិនទូក២ទូក៣ ឯស្រូវថ្លៃ ៣ ថាំង ៤ កាក់ ដឹកដាក់ដល់ជើងកំពង់ បើទិញដល់ផ្ទះថ្លៃតែ ៣ ថាំង ២ កាក់កន្លះ ដ្បិតផ្ទះឆ្ងាយពីជើងកំពង់ ពិបាកដឹកនាំតាមផ្លូវរទេះដែលមិនទាន់មានថ្នល់ ។

ឯសំពត់ផាឱបទេសឯកថ្លៃអស់យ៉ាងរកទិញប្រើការពុំបានទេហើយ វេលាគ្រានោះសុទ្ធតែចិនវារកស៊ីក្នុងស្រុកខ្មែរយើងនេះបានចំណេញច្រើនណាស់ហើយ ប្រាក់ក្នុងស្រុកខ្មែរទាំងប៉ុន្មាននៅដៃវាទាំងអស់ហើយ កាលណាវារកស៊ីបានប្រាក់ច្រើនវានាំយកទៅស្រុកចិន ។

ឯកប៉ាល់ភ្លើងដែលមកដល់ក្នុងស្រុកខ្មែរមុនគេនោះជាកប៉ាល់បារាំងសែស ខ្ញុំបានឃើញជាក់នឹងភ្នែកហើយនៅចាំច្បាស់ដល់ឥឡូវ កាលកប៉ាល់នោះមកដល់កំពង់លួង អ្នកស្រុកផ្អើលឆោឡោ ដ្បិតឆ្ងល់ថាកប៉ាល់ឥតក្ដោងចែវក្រជីងហើយបើកលឿនលើទឹកបាន មនុស្សប្រុសស្រីចាស់ក្មេងរត់ទៅមើលលាន់ ប្រពួនប្រពាន់លើគ្នា ហើយឆ្ងល់មិនយល់ថាដូចម្ដេចសោះស្រាប់តែឃើញរលកបែកពពុះខាងកន្សៃហើយ លឿនពោរទឹកពីក្បាលជះទៅចំហៀងសង្ខាង កើតជារលកបោកទៅខាងមាត់ច្រាំង អ្នកដែលមកមើលទាំងប៉ុន្មាន នោះអស្ចារ្យលាន់មាត់ស្រែកហៃយ៉ាហៃយ៉ា អឺកអធឹក

[16]«សមរ» មកពីបាលី-សំស្ក្រឹតមានន័យថា«សង្គ្រាម, ទ័ព» ។

គឹកកងរំពង មើល មិន ដាក់ ភ្នែក ដោយសារ ឃើញ ផ្សែង ចេញ តាម បំពង់ភ្លើង ហើយឮសន្ធឹកគគុកគគាក់ពីខាងក្នុងកប៉ាល់នោះ ទាំង ហ្លួង ក៏ ស្ដេច មក ជាមួយនឹងនាម៉ឺនមុខមន្ត្រី ហើយ ទ្រង់ យាង ទត មក ពី មាត់ កំពង់ មក ជាច្រើនម៉ោង ទ្រង់ព្រះសន្ធិះសង្ស័យនឹងកប៉ាល់ ព្រោះមិនទាន់ជ្រាប ថាធ្វើដូចម្ដេចខ្លះ អស់ទាំងអ្នកចាស់ប្រជាឈប់ឈរមើលរំពឹងគិត ហើយយល់ថានេះជាមនុស្ស អ្នកស្រុកនគរធំ គេមកដល់ស្រុកយើងហើយៗ មកជួយទំនុកបំរុងយើងស្រុកយើងនឹងបានចម្រើន ផ្លូវវិធីជាថ្មីឡើងទៀត ប្រហែលជានឹងត្រឡប់បានឡើងជានគរធំដូចខ្មែរដើមវិញ នោះ ចាប់ដើមតាំងពីព្រះបាទសម្ដេចព្រះនរោត្តម សោយរាជ្យរៀងមកដល់ឥឡូវនេះ នៅក្នុងស្រុកខ្មែរ វិធីខាងចំណេះវិជ្ជាក៏ចម្រើនហើយ ថ្កើងរុងរឿងជាងអំពីដើមនោះច្រើនណាស់ហើយគ្មានសត្រូវមកបៀតបៀន ពីព្រោះ មាន អ្នក មានបុណ្យ អំណាច ដែល ទំនុក បំរុង យើង គេ គ្រប់ គ្រង ពួកយួន នៅ ស្រុកកូសាំងស៊ីន ហើយ សៀម មក ខ្លាច មិន ហ៊ាន មក បៀត បៀន ទៀត តាំង ពី វេលា គ្រា នោះ រៀងមក ។

ចូរអស់លោកអ្នកទាំងឡាយ នាម៉ឺនក្ដី រាស្ត្រ ក្ដី មើល ហើយពិចារណាគិតឲ្យសព្វទៅឃើញឬទេ ស្រុកយើងសព្វថ្ងៃនេះខុសគ្នានឹងកាល ៤០ឆ្នាំមុន នោះឃើញខុសគ្នាដូចម្ដេចខ្លះហើយ គិតកាលដែល ស្រុកកើតចម្បាំងរាំងជល់ ហើយ ស្រុកឥឡូវដែលបាន និងសុខសប្បាយ ក្សេមក្សាន្តគ្រប់ទីកន្លែង ហើយ ប្រាក់ ក៏ មាន សម្បូណ៌ ក្នុង ស្រុក ខ្មែរ យើង គ្រប់ ផ្ទះសម្បែងក៏មិនដែលដាច់ខ្វះចាយសោះ គង់តែងមានប្រាក់ចាយខ្លះរាល់ផ្ទះ គ្រប់គ្នា ហេតុដែល បានសម្បូណ៌ទាំងនេះពីព្រោះអី នោះ ឃើញ ថា សេចក្ដី អត់ឃ្លានមិនសូវមាន តាំងតែពីកាលបារាំងសែស ចូល មកនៅក្នុងស្រុកយើង ហើយស្រុកយើងក៏មិនយូរឡើយ សម្បូណ៌មានធនធាន អើ ដូច ជា ខ្លួនតានេះអាយុ៤០ឆ្នាំប្លាយហើយៗ ចាំដំណើររឿងព្រេង នាំមកនិទានឲ្យកូនចៅ



ទួតលួតលានៅឯក្រោយឲ្យដឹងរឿងបារាំងសែស នេះកាលពីមុនដូចម្ដេចតមក ទៀតដូចម្ដេចមួយទៀតយើងសព្វថ្ងៃនេះ ចូរ ចាំ កុំ ភ្លេច សេចក្ដី ដែលមនុស្សពីដើមធន់រងលំបាក ទុក្ខវេទនានោះដូចម្ដេចខ្លះហើយកុំភ្លេចគុណបារាំងសែសតែនាំមាត់អាក្រក់គិតការទុច្ចរិតស្ងាត់កំបាំងហើយ នោះ វា នាំ ឲ្យស្រុកនគរយើង ត្រឡប់ទៅកន្លែង ដើម វិញ ដូច កាល គ្រា ដែល ចេះ តែកើតច្បាំង កំសត់អត់ឃ្លាន២០ឆ្នាំម្ដង ១០ឆ្នាំម្ដង ជួនណាឃើញទ័ពយួនមក ជួនណាឃើញទ័ពសៀមមកម្ដងទ័ពមកពីស្រុកនេះម្ដងទ័ពមកពីស្រុកនោះហើយមានទាំងពួកចោរកំណាចកាចផ្ដុំគ្នា លើកជាពួកជាកង លួចប្លន់កាប់ចាក់សម្លាប់គ្នា ហើយដុតផ្ទះសម្បែងវត្តអារាមវិនាសអស់ ។

អើកាលនោះប្រហែល៤០ឆ្នាំមកហើយ នោះ ស្រុក យើង នោះគ្មានអ្វីសោះ សៀម ហើយ និងយួន វា មក តៀតសង្កត់ សង្កិន យើង ហៀបៗ តែនឹងសូន្យឈ្មោះផង ដល់មកឥឡូវនេះ មាន គេស្គាល់ យើង ទាំងពិភព ហើយ សារពើផល ជំនួញ យើងគឺស្រូវ កប្បាស ម្រេច ហើយ និង ត្រីពីក្នុងទន្លេព្រែកបឹងស្ទឹង យើង ដែល កាល ពី ដើម មិន សូវ បាន នាំ ចេញ ទៅ ប្រទេស ក្រៅ ហើយ ច្រើនតែឈ្មួញចិនចូលទិញនោះឥឡូវនេះមានកប៉ាល់ភ្លើងនាំទៅដល់ស្រុកម៉ានីល[17] ស្រុកចិនស្រុកយីពុនស្រុកយ៉ាវ៉ាហើយនិងប្រទេសយូរ៉ុប ។

កាលដើមឡើយគេមិនទាន់ស្គាល់ស្រុកយើង ឥឡូវ គេ មក ពី គ្រប់ទិសដំបន់មកមើលក្រុងភ្នំពេញ នគរធំ នគរវត្តហើយ ចង់ទិញទំនិញអ្វីៗ មាន គ្រប់ ប្រទេសក្រោមមេឃនេះក៏មានឲ្យទិញទាំងអស់ក្នុងស្រុកខ្មែរ កប៉ាល់សាលុប[18]របស់ចិនក្លឹង ឬរបស់បារាំងខ្លះមានសព្វថ្ងៃនេះជាង ៦០ បើកជួញជួលសណ្ដោងទូកទៅមកហូរហែតាមទន្លេបើទៅពីភ្នំពេញទៅព្រែនគរចម្ងាយ

[17]រដ្ឋធានីប្រទេសហ្វីលីពីន ។

[18]ពាក្យ បារាំង សំដៅ កប៉ាល់ តូច "Chaloupe"

តែ២៤ម៉ោង ឯស្រុកព្រៃនគរ នោះកាល ដែល នៅក្នុងដៃយួន វាធ្វើជាម្ចាស់
ស្រុកនោះ យើងមិនហ៊ានទៅសោះ ។

បើទៅពីភ្នំពេញទៅបាត់ដំបងទៅក្រចេះចម្ងាយផ្លូវតែ១២ម៉ោងដល់
ដែលកាលពីដើមចម្ងាយផ្លូវតែ៨ថ្ងៃបើទៅតាមផ្លូវទន្លេធំ ទៅ ស្រុក លាវ
ស្រុកខាង ចម្ងាយ ផ្លូវ សព្វថ្ងៃ តែ ២៤ ម៉ោង ហើយ បើ ឡើង ស្រុក លួង
ប្របាងចម្ងាយផ្លូវមិនដល់២០ថ្ងៃទេ បើទៅតាមផ្លូវសមុទ្រ ពីព្រៃនគរ ទៅ
ស្រុកបាងកកតែ៤ថ្ងៃបើទៅសឹង្គះបួរតែ២ថ្ងៃ ឯស្រុកលង្កា ដែល យើង ស្គាល់
ឈ្មោះដោយសារតែគម្ពីព្រះបាលីនោះយើងមិនដែលនៅសោះកាលពីដើមដ្បិត
ស្រុកឆ្ងាយណាស់សព្វថ្ងៃនេះទៅតែ៨ថ្ងៃដល់ ឯស្រុកបារាំងសែស ចម្ងាយ ផ្លូវ
តែ ២២ ថ្ងៃ ស្រុកខ្មែរយើងសព្វថ្ងៃនេះមិនមែនជាស្រុកដែលឥតនរណាស្គាល់
អ្នកនគរទាំងពិភពគេក៏មិនសល់និងស្គាល់យើង ហើយ នគរ ណា ដែល
យើងមិនស្គាល់មិនដែលឮនិយាយសោះ ឥឡូវនេះយើងស្គាល់ទាំងអស់
ហ្លួងយើងក៏បានស្តេចទៅស្រុកបារាំងសែស ហើយ បាន ចូល ទត ស្រុក
សឹង្គះបួរ លង្កានិងព្រែកជីកធំដែលដៃបារាំងសែសជីកទម្លុះពីសមុទ្រទិសឯកើត
កាត់ទៅសមុទ្រទិសឯលិចព្រែកជីកនោះជាផ្លូវសមុទ្រធំ ក្នុង ១ ឆ្នាំ មាន កប៉ាល់
ភ្លើង ជា ច្រើន ពាន់ បើក ចេញ ចូល ទៅ មក មិន ដែល ដាច់ អស់ ទាំង លោក
សេនាបតីព្រះអង្គម្ចាស់ក្សត្រីនិង ចៅជិតចៅចម អស់ អ្នកក្នុងវាំង ក៏ បាន ទៅ
ឃើញស្គាល់ស្រុកបារាំងឃើញក្រុងប៉ារីសជាទីដីជំនុំស្រុកបារាំងសែស ឯ ក្រុង
ប៉ារីស នោះជាក្រុងធំនឹងគិតគណនា ត្រារាប់ពុំបាន បើរាប់តែរាស្ត្រ ចំណុះ ស្រុក
ក្នុង ទី ដី ជំនុំ ក្រុង ប៉ារីស នោះ ប្រហែល ចំនួន មនុស្ស ២ នគរ ខ្មែរ យើង ទើប
ប្រហែលនឹងមនុស្សក្នុងទីដីជំនុំក្នុងប៉ារីស ១ ហើយ ១ ទៀតកូនខ្មែរយើងក៏បាន
ទៅរៀនអក្សរ ចំណេះវិជ្ជានៅស្រុកបារាំងសែសហើយៗ ត្រឡប់មកវិញ ឡើងជា
មនុស្សចេះដឹង នាំដំណឹងរឿងរ៉ាវពីស្រុកបារាំងសែសយកមកនិយាយមុខគួរឲ្យ
ស្តាប់ដ្បិតស្រុកនោះជាស្រុកកាល មុន ៨០ ឆ្នាំខ្លួនខ្ញុំឪពុកម្តាយ ជីតា ជីដូន ជីទួត



លួតលាយើងមិនដែលឮឈ្មោះសោះអើនេះគឺបារាំងសែសគេបើកលោកបំភ្លឺ
ឲ្យយើង បើគ្មានបារាំងសែសម្ល៉េះសមយើងមិនដឹងការអ្វីជាច្រើនទេ
គ្រាន់តែឃើញថាមនុស្សឃើញតែស្រុកហើយ ឃើញតែចំណេះវិជ្ជាយ៉ាងខ្ពស់
ប៉ុណ្ណឹង ឯឡូវនេះយើង ដឹងស្គាល់ថាបារាំងសែស នេះ ជា អ្នក មានរិទ្ធិ អនុភាព
មានប្រាជ្ញាឆ្លាតច្រើន ហើយការប្រើរបស់អ្វីៗ តែនឹងគ្រឿងម៉ាស៊ីន[19] គ្រឿង
ចក្រឃើញរឹតតែពូកែឡើងទៀត ជិតៗ តែ នឹង មាន រិទ្ធិ ចេស្តា ដូច
ទេវតា ។

គេយកទឹកជាច្រើនមកដាក់ក្នុងឆ្នាំងធំ ដុត ភ្លើង ដាំ ឲ្យ ពុះៗ ជា ខ្លាំង
កម្លាំងទឹកពុះនោះស្ទុះពីក្នុងឆ្នាំង ធាក់វិលកង់ដែលនៅលើផ្លូវដែកឬធាក់
ភ្លៅចក្រា វិលស្លាបចក្រក្នុងទឹក នៅខាងកន្សែកប៉ាល់ អំណាច កម្លាំង
ទឹកពុះនោះគេក៏ប្រើឲ្យវិលកង់រទេះបើកលឿនឯង មិន ចាំ បាច់ ពឹង កម្លាំង
សេះឬសត្វពាហនៈឯទៀត ឲ្យអូសទង់ទាញឡើយ ឯកប៉ាល់ក៏បើកលឿន
ក្នុងទន្លេសមុទ្រ ដោយសារអំណាចទឹកពុះនោះដូចគ្នា មិន ចាំ បាច់
ប្រើក្តោងចែវក្រដឹងឡើយ ។

ពួកកូនខ្មែរយើងដែល បានទៅស្រុក បារាំងសែស ហើយត្រឡប់មកវិញ
និយាយបារាំងសែស ចេះយកធ្យូងថ្មមកដុតហើយបង្ហូតភ្លើងតាមបំពង់ទៅ
គ្រប់ផ្ទះសម្បែង ឯភ្លើងដើរចេញពីបំពង់បង្ហូតនោះភ្លឺដូចភ្លើងចង្កៀង
ប្រេងកាតក្នុងស្រុកខ្មែរយើងនេះ កាលដើមអុជចន្លុះ ប្រនេះ ទៀន
ក្រមួនឥឡូវនេះរាល់ផ្ទះអុជចង្កៀងប្រេងកាតឯប្រេងកាតនោះជាប្រេងអណ្តូង
កើតពីក្នុងដី នៅប្រទេសឆ្ងាយណាស់ដែលកប៉ាល់បារាំងនាំយកមកលក់ក្នុង
ស្រុកខ្មែរ ។ ឯចង្កៀងទាំង៨០០ដែលបំភ្លឺក្រុងភ្នំពេញសព្វថ្ងៃនេះមិនមែនជា
ភ្លើងដែលដុតធ្យូងថ្មបង្ហូតតាមបំពង់ទេ ភ្លើងនេះជាភ្លើងអគ្គិសនី មាន

[19] ពាក្យ បារាំង ថា Machine

ពន្លឺដូចផ្លេកបន្ទោរកណ្ដាល អាកាសដែលបារាំងគេចេះផ្សំធាតុ យកចំហាយធ្វើឲ្យរត់តាមខ្សែលួស ។

អើកាល៤០ឆ្នាំមុននេះ យើងមិនទាន់ដឹងជាបារាំងគេមានខ្សែលួសរាយទៅមករកគ្នា ហើយស្ដាប់គ្នាបានពីចម្ងាយ ឥឡូវយើងឃើញថា គេនិយាយគ្នា ពីស្រុកវៀងច័ន្ទ[20]មកភ្នំពេញ ពីភ្នំពេញទៅលួងប្របាង ពីព្រៃនគរទៅហាន់ណោយ[21] ទៅស្រុកហ្វេ ទៅបាងកក ទៅស្រុកចិន ហើយទៅដល់ស្រុកបារាំងសែសផង តែក្នុងពីរបីមីនុត[22]ស្ដាប់ដំណឹងដឹងការទៅវិញទៅមកដំណឹងដែលរត់តាមខ្សែលួសនោះរហ័សស្មើនឹងជីវិតដែលគិត អើបើគិតសព្វគ្រប់ទៅឃើញថាបារាំងគេមានគុណនឹងយើងមិនតែប៉ុណ្ណោះនៅមានគុណច្រើនជំពូកទៀត បារាំងសែសនេះគេមានប្រាជ្ញាឆ្លាតគ្មានទុញទាល់សល់នឹងអ្វីសោះ គេនាំយកនៅរបស់ដ៏ប្រសើរមកបង្ហាញបំភ្លឺយើង ។

១ទៀតគេនាំយកម៉ាស៊ីនហិបច្រៀងថតសម្លេងភាសាដូចមនុស្សច្រៀងនិយាយគ្នាមែនទែន តាមតែទំនើងចិត្តនរណាចង់ស្ដាប់ចុះ ហើយមានកុនស្រមោលឆ្លុះរូបវិស័យដូចឃើញស្រុកបារាំងសែសផ្លូវថ្លាមនុស្សម្នាដើរទៅមកដូចរូបរស់ដែលគេឃើញក្នុងស្រុកបារាំងសែស ក្រុងប៉ារីសដូចម្ដេច នោះយើងនៅតែស្រុកខ្មែរ ឃើញវិស័យ ដូចយើងបានឃើញស្រុកបារាំងសែសខ្លួនយើង ។

គេចេះធ្វើគ្រឿងថតរូប បើជួលតែបីរៀលបានរូបរបស់ខ្លួនយកមករក្សាទុក ហើយជាប្រយោជន៍បានរក្សារូបឪពុកម្ដាយ ទុកតទៅមុខ ឲ្យកូនដឹងស្គាល់ជារូបជីតាជីដូនដែលស្លាប់ជាអង្វែងរាប់រយឆ្នាំមកហើយនោះ ។

---

[20]រាជធានីប្រទេសលាវ ។

[21]Hanoï

[22]Minute: នាទី ។



គេនិយាយថាបារាំងសែស សព្វថ្ងៃនេះចេះហោះលើអាកាសដោយអំណាចយន្តគោមហោះៗលឿនដូចសត្វហើរ ពាក្យនេះពិតមែនបើមិនជឿសួរមើលចុះអេះ ថាបើបារាំងទាល់ចំណេះហើយតទៅមិនយកយន្តហោះនោះមកឲ្យយើងឃើញទៀត ។

ព្រះបាទសម្ដេចព្រះនរោត្តមជាអម្ចាស់ផែនដី នគរយើងព្រះអង្គបានផ្ញើរាជការផែនដីទាំងប៉ុន្មាន ឲ្យបារាំងសែសគ្រប់គ្រងតាងនេត្រាព្រះឱស្ឋជាមួយនឹងសេនាបតី ចៅហ្វាយស្រុកបាឡាត់ហើយពួកអ្នករាជការខ្មែរជាច្រើនពាន់ដែលជារាជការនៅក្នុងបង្គាប់រេស៊ីដង់[23]បារាំងសែស ឯប្រាក់ទាំងប៉ុន្មានដែលបានមកពីពន្ធគ្រប់ជំពូកនិងប្រាក់ដែលលោះថ្លៃធ្វើរាជការនោះយកមកចាយប្រើការជាប្រយោជន៍ចម្រើនព្រះរាជធានីទាំងអស់ បានប្រាក់នោះដែលយកចាយរៀបចំតែងក្រុងភ្នំពេញដែលសព្វថ្ងៃនេះបានកើតឡើងជាក្រុងល្អថ្កុំថ្កើងដែលពួកខ្មែរទាំងប៉ុន្មាននៅខេត្រក្រៅគេតែងចូលមកមើលនិយាយសរសើរគ្រប់គ្នា ហើយអ្នកប្រទេសក្រៅក៏មានចូលមកមើលលេងនៅភ្នំពេញជាច្រើន ក្រៅពីរៀបចំតែងក្រុងភ្នំពេញនោះរាជការនៅរៀបចំតែងដីទីជំនុំរួមខេត្រដប់អន្លើទៀត ។

ហើយធ្វើថ្នល់ធ្វើស្ពានផ្លូវឲ្យរទេះបរទៅមកដោយស្រួល ហើយនៅគិតនឹងធ្វើផ្លូវថ្នល់ឲ្យគ្រប់ទីដំបន់ក្នុងស្រុកខ្មែរឲ្យបានដឹកនាំជំនួញទំនិញកាត់ទៅលក់ក្នុងភូមិធំៗដោយងាយហើយបានឆាប់ក៏ឆាប់ ឯសោហ៊ុយដឹកនាំទំនិញទៅឯផ្សារធំក៏ថោក ។

១ទៀតគេនិយាយថាគិតធ្វើរទេះភ្លើង ក្នុងរទេះ ១ ទាញយោងបានរទេះ១០កាត់ផ្ទុកទំនិញ ហើយនិងអ្នកដំណើរពីបាត់ដំបងមកស្រុក

---

[23]Résident គឺជាមន្ត្រីជាន់ខ្ពស់បារាំងឈរនៅក្នុងខេត្រក្រុងនិមួយៗ ក្នុងស្រុកខ្មែរយើងសម័យអាណាព្យាបាលបារាំងសែស ។

ភ្នំពេញទៅព្រៃនគរ គេនិយាយគិតថានឹងធ្វើផ្លូវរទេះភ្លើង១ទៀតកាត់ទៅលាវទៅយួនហើយនិងស្រុកសៀមប៉ុន្តែផ្លូវរទេះបររថភ្លើង នោះនឹងធ្វើឲ្យទាន់ឆាប់ភ្លាមនោះមិនបានទេប៉ុន្តែគេថាធ្វើឲ្យបាន ហើយក្នុងរវាងមុន២៥ឆ្នាំនេះនោះស្រុកខ្មែរនឹងមានផ្លូវរថភ្លើងបរទៅមកជាប់គ្នានឹងនគរដែលនៅជុំវិញយើង ឯផ្លូវស្រុកយូរ៉ុប ស្រុកចិន ស្រុកយីពុន នោះមានផ្លូវកប៉ាល់ ភ្លើងកប៉ាល់ជំនួញស្រាប់ហើយ កាលណាមានផ្លូវគ្រប់បរិបូណ៌ នោះខ្មែរយើងក៏នឹងត្រឡប់ជាទីប្រជុំផ្លូវជំនួញធំ១ ហើយនគរក៏នឹងបានជាធំថ្កុំថ្កើងឡើងសមគួរតាមលំដាប់ស្រុកបុរាណខ្មែរដើមវិញ ពូជអំបូរកូនចៅខ្មែរដែលតំណតវង្សត្រកូល មិនបង់កំណើតជាតិ ដោយសារក្រឡាប់ឡើងបានជាពូជអ្នកនគរធំនឹងគេវិញ ។

រីឯទ័ពទីងចម្បាំងវាំងដល់យើងអស់មានអំពល់សេចក្តីភ័យ បារម្ភដ្បិតបារាំងសែសគេគិតតែបង្រៀនប្រដៅចំណេះវិជ្ជាការឲ្យយើង រួចខ្លួនជាខ្មែរអ្នកជាហើយ ខ្លាំងពូកែ គេសង់សាលាបង្រៀនអក្សរបារាំងគ្រប់ទីកន្លែង ហើយគេទំនុកបំរុងវត្តអារាមដែលបង្រៀនអក្សរសត្រាបាលីខ្មែរហើយ គេចែករង្វាន់ឲ្យកូនសិស្សណាដែលខំរៀនហើយ គេសុំតែគ្រប់គ្រងយើងជាមួយនឹងនាម៉ឺនខ្មែរណាដែលមានចិត្តស្លូតត្រង់ ហើយរើសយកខ្លួនឲ្យធ្វើជានាម៉ឺនឲ្យបានចម្រើនក្នុងនគរ ហើយឲ្យយើងរាស្ត្រខ្មែរទាំងប៉ុន្មានបានចម្រើនសេចក្តីសុខគ្រប់គ្នាឯខ្លួនតានេះចាស់ហើយ គិតរំពឹងច្រើនៗ ទៅឃើញទៅដល់របស់ដែលខ្លួនបានឃើញកាលនៅក្មេងគិតទៅដល់របស់ដែលបានឃើញកាលខ្លួនធំហើយៗ គិតមកដល់របស់ដែលភ្នែកខ្លួនឃើញសព្វថ្ងៃនេះគិតឃើញម្តងទៅមុខគួរឲ្យកោតខ្លាចបារាំងសែសនេះណាស់ មកកោតនឹងមានចិត្តសង្វាតឧស្សាហ៍ ប្រាជ្ញាឆ្លាត ឯខ្មែរយើងឃើញខ្ជិលច្រអូសក្នុងខ្លួនក្នុងចិត្តបន្តិច ឯបារាំងសែសចូរកូនចៅមើលគេចុះឃើញទេ តាំងពីប្រមាណ១៥ឆ្នាំរៀងមកដែលគេស្តីរាជការគ្រប់គ្រងស្រុកយើងដែលមកដល់សព្វថ្ងៃនេះគេធ្វើបានសេចក្តីរួតរះ



ហើយគំនិតគេល្អ គេគិតតែឲ្យយើងចម្រើនបាន សេចក្តីសុខ ឲ្យយើងចម្រើនមានទ្រព្យសម្បត្តិហើយនិងរៀបចំទីដីស្រុកយើងឲ្យរបបរៀបរយតាមដោយវគ្គដោយស្នើ[24]ហើយគេបំបាត់មិនឲ្យមានខ្ញុំកញ្ចះអ្នកងារអង្គរក្សទ្រមាក់ជៀះគុន(?)ហើយគេចែកដីឲ្យយើងរាល់គ្នាធ្វើស្រែចំការរកស៊ីសព្វថ្ងៃនេះដីរបស់នរណាអ្នកនឹងធ្វើជាម្ចាស់ដី ហើយផលស្រែចំការច្បារដំណាំយើងក៏លក់បានថ្លៃជាងពីដើម ។

១ទៀតមុខឲ្យសរសើរបារាំងនេះ ចិត្តគេ អីក៏ជានឹងអ្នកកំសត់ទុគ៌តអ្នកមានជម្ងឺរោគាព្យាធិម្លេះៗ គេចាត់គ្រូពេទ្យដាក់ឲ្យនៅគ្រប់ទីរេស៊ីដង់[25]រួមខែត្រឲ្យចាំបីបាច់រក្សាមើលថែទាំអ្នកជម្ងឺទាំងនោះ ក៏ឃើញថាចិត្តគេល្អមែនហើយ ឯយើងខ្មែរដែលនឹងដឹងគុណគេនោះគឺយកចិត្តឈឺឆ្អាលជួយគេតាមគំនិតដែលគេគិតធ្វើការអ្វីៗ ឯសេចក្តីដែលឈឺឆ្អាលជួយការគេនោះ ទុកប្រៀបដូចជាយើងស្រឡាញ់ស្រុកយើងធ្វើរាជការតបស្នងសងគុណនគរយើង ។

កាលដែលបារាំងសែសទើបមកដល់នោះនគរយើងកាន់តែតូចណាស់ទៅហើយនៅតែពីត្រឹមខែត្រពោធិ៍សាត់ទៅទល់នឹងព្រែកជីកខែត្រពាមដែលភាសាយួនវាឲ្យឈ្មោះហៅព្រែកវិញតែនៅសល់ពីត្រឹមខែត្រសំបូរណ៍ទៅទល់នឹងខែត្រវំដួល ហើយនិងស្រុកព្នងស្មៀងទៅទល់នឹងមាត់សមុទ្រខាងកើតហើយខាតទាំងខែត្រកោះកុងដែលបានទៅសៀមនោះមិនដឹងជាដំណើរដូចម្តេចក៏បានជាកាន់តែតូចទៅដូច្នោះ ឯសព្វថ្ងៃនេះស្រុកយើងខ្មែរត្រឡប់

---

[24] ស្រទាប់, សង្កាត់... ។

[25] យើងរក្សាអក្ខរាវិរុទ្ធដើម, ជួនឃើញសរសេរ «រេស៊ីដង់» គឺត្រូវនឹងពាក្យបារាំង Résident.

បានជាធំវិញ កាលដែលបារាំងសែសទើបមកដល់នោះមិនបានធំប៉ុណ្ណឹងទេ សព្វថ្ងៃនេះបានធំពាក់កណ្ដាលថែមទៀត ។

កាលក្នុងរាជព្រះបាទព្រះហរិរក្សរាមា (ព្រះអង្គឌួង) ឬ កាលក្នុងរាជព្រះបាទសម្ដេចព្រះនរោត្ដម (ហ្លួងសុរណ្ណកោដ្ឋ) នោះស្រុកយើងខ្មែរក៏មិនទាន់បានធំប៉ុណ្ណឹង ៦សៀមពីព្រោះតែបារាំងសែសគេសង្កិន បានជាវាប្រគល់ខែត្របាត់ដំបងមង្គលបូរីស៊ីសូផុន សៀមរាបដែលនៅខាងម្ខាងទន្លេសាបទាំងប៉ុន្មានឲ្យយើងវិញ រី៦ខែត្រកោះកុងដែលនៅត្រើយមាត់សមុទ្រខាងលិចក៏សៀមវាប្រគល់មកឲ្យយើងវិញដែរ ៦ខែត្រទន្លេរពៅម្លូព្រៃដែលនៅជាខាងជើងនគរខ្មែរយើង ក៏សៀមវាប្រគល់មកឲ្យយើងវិញ១ទៀតស្រុកបារាំងសែសគេយកស្រុកលាវបានមកពីដៃសៀម ហើយគេប្រគល់ខែត្រស្ទឹងត្រែងមកឲ្យខ្មែរវិញ បើគ្មានស្រុកបារាំងសែសម្ល៉េះសមយើងនឹងយកខែត្រទាំងនោះមកបញ្ចូលក្នុងស្រុកខ្មែរវិញមិនបានឡើយ កាលនៅក្នុង ៨០ឆ្នាំមុនយើងមានបាបកម្មវាផ្ដន្ទាយើងឲ្យសូន្យឈ្មោះទៅជាចំណុះសៀម ហើយទីដីនគរយើងក៏ទៅជាដីសៀម រី៦សព្វថ្ងៃនេះខែត្រយើងក៏បានធំហើយរឹតតែធំឡើង ៦នគរយើងក៏ឡើងជាមហានគរធំ ដូច្នេះ យើងមានតែខំឧស្សាហ៍ធ្វើការបន្តិចនឹងអាលបានឡើងស្មើនឹងអ្នកនគរធំនឹងគេ ។ អើយើងបានមានបុណ្យសំណាងទាំងម្ល៉េះនេះដោយសារបារាំងសែស បើគ្មានគេប្រហែលជាយើងមិនកើតជាអ្វីសោះ សព្វថ្ងៃនេះបារាំងសែសគេមានគុណនឹងយើងបានជាយើងមានសំណាងប៉ុណ្ណឹង ហេតុដូច្នេះទើបបានជាតាក៏គិតតែងជានិទានតាមរឿងដំណើរដែលមានរឿងមកទុកទូន្មានបញ្ចូលចិត្តអស់អ្នកទាំងពួងដែលជាសាសន៍ខ្មែរដូចគ្នាឲ្យស្រឡាញ់រាប់អានទុកចិត្តបារាំងសែសដោយស្មោះត្រង់កុំញញើតគិតវាមុខវាក្រោយឡើយ ដ្បិតបារាំងសែសនេះជាមិត្រមេត្រី ជាពំនឹង ហើយជាគ្រូយើងផង ។



សេចក្ដីដែលបានតែងជាបរិយាយ រាយតាមដំណើរមកនេះក្រែងខាតខុសលើសលោះ ឬពុំគោរម្យ[26]សមពិរោះដោយបទវាចាសេចក្ដី សូមអស់លោកអ្នកទាំងឡាយអភ័យទោសដោយសារប្រាជ្ញាស្មារតីតិចចំណោះក៏ឱនថយហើយខ្លួនក៏ចាស់ជរាមានតែចិត្តបរិសុទ្ធស្លូតត្រង់ ស្រឡាញ់ទឹកដីរបស់ខ្លួន ទើបតែងតាមដំណើរទុកឲ្យអ្នកក្រោយមើលស្ដាប់តទៅព្រោះចិត្តសង្ឃឹមថារាជការបារាំងសែសនឹងចាត់ចែងរៀបចំនគរយើងឲ្យឡើងជានគរធំមានបុណ្យអំណាចកូនចៅនៅ៦ក្រោយ គង់តែនឹងដឹងៗឃើញតទៅ បានជាតែងគិតធ្វើសេចក្ដីដូច្នេះ នេះព្រោះតែចិត្តខ្ញុំគិតតែខាងល្អ បើពុំគួរសូមអភ័យទោស ។

តែងក្នុងចុល្លសករាជ១២៦៩នព្វស័ក កាលតាអាយុបាន៨០ឆ្នាំប្លាយហើយ ។

[26]គោរមឬគោរម្យ («សំស្ក្រឹត-បាលី) មានន័យថា «វាចា, សំដី, សូរស័ព្ទដែលគួររីករាយ...»

# បណ្ដាំតាមាស

(ឯកសារថតដោយចង់រក្សាអក្ខរាវិរុទ្ធដើម)

Conseil Ta Meas

# រឿងបណ្ដាំតាមាស





# រឿងបណ្ដាំតាមាស

១ តាមខ្ញុំឈ្មោះមាស ជាចាស់ព្រឹទ្ធាចារីយ៍ អាយុស្មជាង ៨០ ឆ្នាំហើយ កើតក្នុងឆ្នាំជូតសំរិទ្ធិស័ក្យ ចុលសក្ការាជ ១១៩០ បើគិតជាស័ករាជបារាំង ត្រូវថែមឡើង ១ ទៀត ទើបត្រូវនឹងឆ្នាំ ១៨២៨ តែងជាពាក្យបណ្ដាំនេះទុក ឲ្យកូនចៅនៅឯក្រោយ ចូលចាំមគ្រប់គ្នា ឲ្យប្រាប់គ្នាតៗទៅ

កាលដើមឡើយអាពុកខ្ញុំ ធ្វើជាបាឡាត់ខែត្រលង្វែក ជាខែត្រដែរភាឈ្មោះ.ជីតាខ្ញុំធ្វើចៅហ្វាយស្រុក នោះខ្ញុំទាន់ជីតាខ្ញុំ គាត់ច្បាំងនិងយួន កាលរាជហ្លួងអង្គមី ហើយគាត់បាត់បង់ក្នុងទ័ព តមកទៀតអាពុកខ្ញុំ គាត់នាំកងទ័ពទៅជៀញយួនៗ ក៏បាក់រត់ខ្ចាត់ខ្ចាយទៅគ្រប់ទិស ឯខ្លួនគាត់ក៏បាត់មិនដឹងជាទៅឯណា មិនឃើញគាត់ត្រឡប់មកផ្ទះវិញ ជីដូនខ្ញុំគាត់បាត់បង់

ជាង ១១ ឆ្នាំ ១២ ឆ្នាំ មុនជីតាខ្ញុំ នៅកណ្ដាលផ្លូវដែរទៅពីបាត់ដំបងទៅបាងកក ដ្បិតកាលណោះពួកកងទាព់សៀម កៀរគាត់តាមទៅជាឈ្លើយ ឯម្ដាយខ្ញុំគាត់បាត់បង់ នៅវេលាដែរយួនលើកមកលុកប្លន់បន្ទាយឈង្វែក បងប្អូនប្រុសខ្ញុំ ៣ នាក់ អតិចូកម្មក្នុងទីបំម្បាំង កាលណោះទៅច្បាំងជាមួយនិងមាគាត់ ២ នាក់ ហើយនិងបងប្អូនជីដូនមួយច្រើននាក់ ដែរតាមពួកកងទាព់ស្រុះបិត្រគ្នាទៅច្បាំង ឯខ្លួនខ្ញុំបួលច្បាំងនឹងគេបាន ៣ ឆ្នាំ ដ៏រ៉ាប់ទាល់តែស្រុកសានត្រាន ហើយប្លង់អង្គខ្លួងបុះសន្យា ធ្វើជាស្ពានមេត្រីនិងសៀមនិងយួន

នៅវេលានោះខ្ញុំក៏ធំមានអាយុស្មក្រែល ល្មមឃើញស្គាល់តាមការត្រឹមដុំពុកបាន ហើយបានយល់ច្បាស់ដែរពួកតាមុិន ៗ គេនិយាយគ្នានៅប្រាប់ខ្ញុំ ៗ ចាំមបានទាំងអស់

ស្រុកកាលណោះបាក់បែកក្រៃទាល់ក្នុងមួយភូម ៗ រកព្រាក់មួយរៀលគ្មាន រត់បោលស្រែចំការច្បាដំណាំមខានដាំមផ្ទះរាស





ស្ងួតត្រីសសាប ព្រោះខ្លាចក្រែងយួនសៀម វាមកគុំហែងច្រូតយកស្រូវក្នុងស្រែ ដើមដូងដើមស្លា និងដើមឈើស៊ីផ្លែទាំងប៉ុន្មាន កាប់ហោលអស់ជាងពាក់កណ្ដាល ហើយក្នុងភូមដែលជីតា ដែលអាពុកខ្ញុំគាត់ធ្លាប់ឃើញស្គាល់ ពីដើមមានផ្ទះ ១៥០ នោះឃើញនៅតែផ្ទះ ៦០ ផ្ទះ ៥០ ផ្ទះ ២៥ វិញ ឯរាស្ត្របំណុះស្រុក ក៏តិចជាងពីដើម ពួកសមណះជីព្រាហ្មណ៍កើតទុក្ខវេទនា ព្រោះវាលុកប្លន់ព្រះវិហារអារ៉ាម ជន្ទួនយកព្រះពុទ្ធរូបណាដែរជាមាស ជាប្រាក់ ជាសំរិទ្ធ ហើយវាដុតព្រះវិហារវត្តអារ៉ាមជាច្រើនអន្លើបាំ វត្តណាដែរនៅសល់នោះរកដំបូលគ្មាន ដំបូលនោះស្រុតបាក់ ធ្លាក់ទៅគ្របលើអាសនះព្រះ រកន័ណានិងមានចិត្តគិតជួសជុលគ្មាន ព្រោះរវល់តែនិងច្បាំងរាំងដល់រៀងមកជាប់ ៤០ ឆ្នាំ ស្រុកភូមបាក់បែក រត់បោលស្ងាត់ស្ងួនឈឹង មុក្ខគួរឲ្យស្រៃងេះស្រណោចខ្លោចផ្សាណាស់ ណាវេទនានិងស្រី ដែលមានកូនតូច ៗ អង្គុយឱបក្បាលជង្គង់ មុក្ខប្រមឹសមើលតែមុក្ខកូនភ្លឹះ ៗ

លុះបានស្រុកសានត្រាន បានចុះសន្យាជាស្ពានមេត្រី នោះហ្លួងអង្គឌួង បានស្នើរាជជាស្តេចហើយ នោះរាស្ត្ររាល់គ្នាគ្រាន់មានចិត្តសង្ឃឹម ហើយគេឡើងសរសើរថាស្តេចល្អទ្រង់ធម៌ ព្រះទ័យសប្បុរសជ្រះថ្លាដឹងអធ្យោកអធ្យាស្រ័យ ប៉ុន្តែស្រុកយើងកាលនោះខ្សត់ណាស់ អស់អាណាប្រជានុរាស្ត្រលំបាកក្រៃពេកពន់ប្រមាណ ប៉េះតែនៅទ្រាំមចាំមសៀមពុំបានធ្វើការរកស៊ីអ្វីសោះ

ឯខ្លួនខ្ញុំកាលនោះក៏ក្រីណាស់ ហើយគ្មានញាតិផៅសាច់សន្តានញៀងលានសោះ ឯចំណែះវិជ្ជាការក៏ឱនថយ ស្គាល់តែសេចក្តីទុក្ខសោកវេទនា ក៏មានចិត្តកាត់ដំឡាសទ្វាចង់បួសស្រេចហើយក៏ចូលឧបសម្បទក្នុងសំណាក់ព្រះពុទ្ធសាស្នា នៅក្នុងអារ៉ាម ១ ក្នុងក្រុងឱដុងមានជ័យ ដើម្បីនឹងបានមគ្គផលទៅជាតិក្រោយកុំឲ្យអកុសល់ដូចជាតិនេះហើយនឹងបានរៀនសូត្រធម៌អាត្ថស័ត្រាបាឡីផង រួចចុះថែមទាំងអកុសល់ ឯក្នុងវត្តសោតក៏រក





រៀនធម៌អាត្ថស័ត្រាបាឡីគ្មាន ភ្លើងនេះខូចអន្តរាយខ្លះ សៀមវាលួចយកខ្លះ យួនវាបំផ្លាញខូចខ្លះ ឯក្នុងវត្តប្រៀងគដែរខ្ញុំបួសភិក្ខុនោះសោត ក៏មាននៅសល់តែលោកសង្ឃល្ងង់ខ្លៅ ពុំមានគិតរកស័ត្រាវិន័យ និងគម្ពីរព្រះអភិធម្មព្រះត្រៃបិដកឡើយ

ឯកើតច្បាំងក្នុងស្រុកខ្មែរ ហើយចុះសន្យាធ្វើស្ពានមេត្រីរួចហើយ នោះពួកមហាសត្រូវយើងទាំងសង្ខាង គឺស្តេចសៀម ហើយនិងស្តេចយួន វានៅតែកួនយកដីយើងទៀត ឯស្តេចសៀមយកខេត្តចំណែកខាងជើង គឺស្រុកសៀមរាប មានគរធំ ក្រុងស្រុកខ្មែរយើង ហើយស្រុកបាត់ដំបង ម្លូរព្រៃ ទន្លេរពៅ ហើយនិងខេត្តយើងខ្មែរទាំងប៉ុន្មាន ដែរនៅមាត់ស្រមុទ ខាងទិសបស្ចិម ឯស្តេចយួនយកដីដែនស្រុកខ្មែរទាំងប៉ុន្មាន នៅខាងត្បូង គឺព្រៃនគរក្លូសាំងស៊ីនសព្វថ្ងៃនេះ រហូតទៅដល់ទល់និងព្រែកជីកខេត្តពាមខាងឯលិច ខាងឯកើត យករហូតទៅទន្ទឹមនិងក្រុងភ្នំពេញ ។ ឯស្តេចម្ចាស់ដែនដីយើងលោកកើតទុក្ខព្រួយព្រះទ័យ

ដូចជារាស្ត្រដែរ ព្រោះទ្រង់ឈ្វេងយល់ថាសៀមហើយនឹងយួនវា
គិតយកស្រុកខ្មែរ បន្ទួលក្នុងស្រុកវារាល់គ្នា ប៉ុន្តែវាបន្ទួលមិនទាន់
បាន ព្រោះវាស៊ីត្រូវនឹងគ្នា ហើយបែកគ្នាមិនកើត ដ្បិតវាចង់បាន
តែទាំងអស់រាល់ខ្ទួន ៗ ម្ចាស់យើងលោកព្រួយព្រះទ័យ ១ ជុំពូក
ទៀត ព្រោះសៀមវាចង់ទំនុកបំរុងលោក ៗ ពុំសព្វព្រះទ័យ
ព្រោះវាមិនទុកលោកជាស្តេចផែន្ដីស្រុកខ្មែរ វាទុកលោកដូចជា
ចៅហ្វាយស្រុកខ្មែរវិញ ឯយួនវាទុកលោកជាចំណុះវា ហេតុដូច្នេះ
ព្រះអង្គក៏រឹតតែព្រួយព្រះរាជហឫទ័យ ក្រែងកើតចំម្បាំងជាថ្មីទៀត
ក្រែងស្រុកខ្មែរនឹងវិនាសអន្តរាយ ហើយផុតមានអស់ពូជខ្មែរក្រែងនៅ
តែសៀម ឬនៅតែខ្មែរដែរទុកសក់ប្លង់ពីក្រោយ ដូចជាតួងស្មៀង
យកកន្សែងជួតក្បាលដូចជាយួន

ឯហ្លួងយើងកាលោះលោកបេះតែខំមប្រឹងតាមការ ទ្រង់
បាត់ឲ្យបំឡុងស្ត្រាបាឡីប្រាប់ទំលាប់ហើយស៊ីបសួររកពង្សាវតារ
ដែលនៅសល់ឃើញទាំងប៉ុន្មាន ឲ្យយកមកចំឡងទុក ព្រោះ





ពេលក្រោយមានព្រះរាជហឫទ័យ ដើម្បីនឹងរៀបចំស្រុកខ្មែរយើង
ឲ្យរបៀបរៀបរយ តែទ្រង់នៅមានព្រះវិតក្កក្រែងតទៅមុខសៀម
ហើយនឹងយួនវាយកស្រុកយើងខ្មែរបែកគ្នា ទ្រង់ព្រះចិន្តាតែម៉្លោះ
ទើបទ្រង់ឈ្វេងយល់ថា នឹងពឹងរកស្រុកប្រទេសយុរ៉ុបណា ១
ឲ្យជួយទំនុកបំរុង តទ្បូវនឹងទៅពឹងបុស្សអាំងក្លេស ព្រោះ
អាំងក្លេសបានស្រុកភ្លឹង ហើយនឹងស្រុកសឹង្គះបូរហើយ តទ្បូវ
នឹងទៅពឹងបុស្សវីឡាន្ដា ទ្រង់ពុំសព្វព្រះទ័យ ដ្បិតវីឡាន្ដាធ្វើជា
ចៅហ្វាយនៅស្រុកយ៉ារ៉ា ស្រុកស៊ូម៉ាត្រាហើយ តទ្បូវនឹងទៅពឹង
បុស្សអេះស្ប៉ាញ៉ុល ឬប៉ូតុយកេស ដ្បិតសាសន៍ទាំងនោះពុំពូកែ ទ្រង់
ព្រះចិន្តាតែម៉្លោះស្រេចហើយ ក៏ទ្រង់សំរេចថានឹងពឹងបារាំងសែស
ដ្បិតបារាំងសែសគ្មានស្រុកចំណុះនៅប្រែបស្រុកខ្មែរ

១ ទៀតកាលពីដើមទ្រង់គង់នៅស្រុកបាងកក បានជួប
នឹងបារាំងសែស ហើយទ្រង់ទតយល់រីករាយ មិនធ្មេងកន្ត្រើង
នឹងតំណាក់ទាក់រាប់អានអ្នកទាំងពួង ហើយចិត្តថ្លើមក៏មានផុម្ម

សម្បូរស ទើបទ្រង់សំរេចហ៊ាសុំមពឹងបារាំងសែស ឲ្យជួយ ទំនុកបំរុង ការព្រះរាជស័ត្រូវយួននៅស្រុកព្រៃនគរ ហើយនិងការ ព្រះរាជស័ត្រូវសៀមជាដើម ព្រោះមានខាល្ងងមកឈរ អម ព្រះអង្គនៅស្រុកឧដុងមានជៀ្យ ទ្រង់មានព្រះទ្បៃអៀនខ្មាស ចង់ ឲ្យរ៉ូតរួចពីដៃ្យសៀមនោះណាស់ ទើបទ្រង់តែងរាជទូត ២ នាក់ ឲ្យនាំមព្រះរាជសារ ទៅដល់កុងស៊ុលបារាំងសែស នៅស្រុក សឹង្គះបួរ ១ ច្បាប់ទៀតទៅដល់អំម្ប៉ឺរ៉ឺស្តេចបារាំងសែស ក្នុង សេចក្តីព្រះរាជសារនោះ ហ៊ាសុំមពឹងបុណ្យស្តេចបារាំងសែស សុំមឲ្យស្តេចបារាំងសែស តែងរាជទូតចូលមកនិងចុះសញ្ញាគ្នា នោះស្តេចបារាំងសែស មិនឃើញតែងរាជទូតឲ្យមកចុះសញ្ញា ស្រាប់តែបាត់កងទាព់មកច្បាំងនិងស្តេចទេព្ភា ស្រុកយួន ហើ្យ វាយ្យកស្រុកព្រៃនគរ ហើ្យយកស្រុកកូសាំងស៊ីន បានពាក់– កន្ទាលជាមុន ទើបយកពាក់កន្តាលទៀត រៀងទៅទល់និង ខែត្រពាម នោះហ្លួងក៏មានព្រះរាជហារទ្បៃអំណរ ដោ្យសារ





ឃើញស្រុកបារាំងសែស លើកទាព់មកវាយ្យដេញយួន កាល ហ្លួងសុគត់ ក្នុងឆ្នាំមមែឯកស័ក្ក ចុះសករាជ ១២២០ ឆ្នាំ

គិតរំឭកឃើញទាំងណើរទាំងនោះសព្វគ្រប់ទៅខ្ញុំមានចិត្ត អំណរនិងបារាំងសែស ដែលមកដេញយួន វាជាស័ត្រូវនិងយើង ខ្មែរ វាវាយ្យផ្តើមសង្កត់សង្កិនស្រុកយើង ជិត ៗ តែនិង ៣០ ឆ្នាំ ហើ្យវាតាំងស្តេចស្រី ៗ បីព្រះអង្គ ១ ព្រះអង្គជាឯករាជ ១ អង្គជាទី ឧបរាជ ១ អង្គទៀតជាទីព្រះកែវហ្វា ហើ្យវាធ្វើបន្ទាយវាយ ពេញតែស្រុកខ្មែរ បិតឹបខ្មែរឲ្យធ្វើយោបាយស្រុក ឲ្យទុកសក់ ស្លៀកពាក់តាមសាស្ត៍វាជាយួន ហើ្យវាគិតផ្លាស់ពេឈ្មោះខែត្រ ស្រុកខ្មែរ ដាក់ឈ្មោះជាយួន ប៉ុន្តែនៅវេលានោះយើងខ្លបតែ បារាំងសែស កាល្ណាវាស្រុកយួនរួបហើ្យក៏ត្រឡប់ទៅស្រុកវិញ មិនមកជួយយើងខ្មែរ

ឯបារាំងសែស ដែរលើកទាព់ទៅច្បាំងនិងស្តេចយួននោះ បើអ្នកទាំងឡាយ ពុំដឹងជាហេតុដើមទងដូចម្តេច នោះខ្ញុំនិង

អធិប្បាយរឿងណោះជូនស្តាប  តាមដែរខ្ញុំបានដឹងឮគេនិយាយរាល់គ្នា  នៅវេលាគ្រានោះ  ជាកាលណោះប្រហែលជាង ១២០ ឆ្នាំមកហើយ  នោះកូនស្ដេចស្រុកយួនប្រាំងនិងពួកក្បត់  ដែលគិតបាស់ ប្រាំងដណ្ដើមយករាជស្រុកយួន  ក៏កាលណោះមានពួកសេតាទាហ៊ានបារាំងសែស  ហើយនិងពួកកូប៉ាល់ចំប្បាំងទាំងអស់ជាង ៤០០ នាក់  ចូរចិត្តយកអាសារធ្វើរាជ្ការថ្វាយ  ហើយប្រាំងនិងពួកក្បត់នោះយករាជថ្វាយវិញ  ឯពួកបារាំងសែស  ដែរប្រដៅសាសនាគ្រិះស្ដាំង  ទៅអន្ទងយកពួកសេតាទាហ៊ាន  ទាំងនោះមកជួយស្ដេចស្រុកយួន  ព្រោះតែពួកប្រដៅសាសនាទាំងនោះមានចិត្តស្លូតត្រង់និងស្ដេចយួន  ធ្វើរាជ្ការថ្វាយស្ដេច  ហើយអស់អាណាប្រជានុរាស្ត្រយួន  ក៏ស្រឡាញ់រាប់អានពួកប្រដៅសាសនាទាំងនោះណាស់  ហើយមានរាស្ត្រយួនប្រុសស្រីជាច្រើន  លែងចោលសាសនារបស់ខ្លួន  រត់ចូលសាសនាបារាំងសែស

ឯពួកសេតាទាហ៊ាន និងពួកបារាំងសែសទាំងប៉ុន្មាន ដែរពួកប្រដៅសាសនាបង្គាប់បញ្ជា នោះក៏មានចិត្តក្លាហាន ហើយនាំ





ពួកកងទាត់ស្ដេចយួនប្រាំងនិងពួកក្បត់ ។  ក៏អប្បរាជ័យចាញ់បាក់បបខ្ចបខ្ចាយ ហើយអ្នកស្ដេចទេព្វយ៉ាឡុង ក៏បានឡើងសោយរាជជាស្ដេចគ្រប់គ្រង  មិនតែក្នុងចំណែកនគរយួន  ហើយនិងស្រុកកូសាំងស៊ីនឡើយ  ទាំងស្រុកតុងកឹង  ក៏បានចូលមកក្នុងព្រះរាជអាណាចក្រទាំងអស់  ឯនគរស្ដេចស្រុកយួនក៏បានធំទូលាយឡើង  ខាងឯជើងរហូតហួសស្រុកចិន្ដទៀត ទៅទល់និងស្រម៉ុងខាងកើត ដែរគេហៅស្រម៉ុងសៀម  ពីខាងទិសនិរតី  ទល់និងខែត្រពោធ  ឯនគរយួនកាលណោះបំរើនធំទូលាយជាងធម្មា

រីឯស្ដេចយ៉ាឡុងជាស្ដេចយួន  នោះស្លាប់ក្នុងឆ្នាំហោះ ឯកស័ក ស័ករាជ ១១៨១ ឆ្នាំ មានកូនប្រុស ១ ឈ្មោះមិញម៉ាង ឡើងសោយរាជតវង្ស  ឈ្មោះស្ដេចមិញម៉ាងនោះឯង  ដែរចាត់កងទាត់យួនឲ្យមកច្បាំងនិងយើងខ្មែរ  កាលណោះជាចំប្បាំងធំណាស់  នគរយើងខ្មែរនេះហៀបតែនិងបានដៃយួន

ឯស្តេចយួននោះជាមនុស្សកុំណាច ប្រណៃនគិតឆ្លុលហ្មនិះ ប៉ែះតែរៀសខ្លួន មិនទុកចិត្តនណា ហើយតាំងធ្វើទុក្ខបុកម្នេញ ពួកសេនាទាហានបារាំងសែស ដែលមានសះគុណជួយធ្វើរាជ្ការ ខ្មោចស្តេចអាពុក នោះពួកសេនាទាហានបារាំងសែស ជំនួនៈ ១២ នាក់ ដែរចូលមកនៅ ៗ ធន់មិនបានស្លាប់អស់ សល់តែ ២ នាក់ ៗ ក៏ធន់មិនបាន ហើយនាំមប្រពន្ធយួន ហើយនិងកូនដែរ កើតពីប្រពន្ធយួននោះត្រឡប់វិលទៅស្រុកបារាំងសែសវិញ

កាលក្រោយពួកបារាំងសែសចេញទៅនោះ ស្តេចយួន តាំងតែសង្កត់សង្កិនធ្វើបាបពួកលោកសង្ឃបារាំង ហើយនិងពួក យួនដែរចូលសាសន៍គ្រិះស្តាំង ហើយឲ្យចាប់ចងក្រពើធ្វើបាប និង ប្រហារជីវិតលោកសង្ឃបារាំងសែស ហើយនិងពួកចូលសាសន៍នៅ ក្នុងស្រុកយួន ស្រុកតុងគឹង ស្រុកកូសាំងស៊ីនជាច្រើន

ស្តេចនគរបារាំងសែស បានឲ្យរាជទូតនាំជាច្រើនដង ច្រើនគ្រា ប៉ុន្តែស្តេចយួនមិនទទួលស្តាប់ យកចិត្តទុកដាក់សោះ





ប៉ែះតែគិតធ្វើបាបពួកប្រជោសាសន៍ ហើយនិងពួកចូលសាសន៍ទៅ មិនបន្ថែមម៉្លោះសោត ស្តេចយួនក៏នៅរឹងទទឹង មិនទទួលឲ្យជួប សំដីនិងរាជទូតនគរបារាំងសែស ហើយមិនព្រមទទួលមើល ស្តាប់ព្រះរាជសារ ដែរស្តេចនគរបារាំងសែស ឲ្យរាជទូតនាំ មកនោះផង

ឯស្តេចយួនឈ្មោះមិញម៉ាំងនោះ ស្លាប់ប្រហែលក្នុងឆ្នាំ ព្រះបាទម្ចាស់អង្គឌួងយើង បានឡើងសោយរាជសម្បត្តិគ្រប់គ្រង ក្រុងកម្ពុជាធិបតី ហើយនៅវេលាគ្រានោះគេប៉ែះតែក្រែងថាស្តេច ស្រុកបារាំងសែស និងចាត់កងទាព់ឲ្យមកផ្ចាញ់អស់ពួកយួន ដែរ វាពត្រិតបទអាក្រក់ខុសនិងធម្ម.

លុះដល់ស្តេចធៀវទ្រី បានឡើងសោយរាជក្នុងស្រុកយួន នោះឃើញអន់កុំណាច និងពួកចូលសាសន៍គ្រិះស្តាំង ហើយអន់ គុំកួនគុំគួននិងពួកប្រជោសាស្នាគ្រិះស្តាំង ហើយបានបើកពួក ប្រជោសាស្នា ដែលខ្មោចស្តេចអាពុកចាប់ដាក់គុកទាំងប៉ុន្មានៗ

នោះប្រគល់ខ្លួនឲ្យកុំម៉ីខ្លាំង ត្យកូប៉ាល់ចំម្បាំងបារាំងសែស ទាំងអស់ បុន្តែអំណាសត៍មកក្រោយទៀត ស្តេចធៀវទ្រីក៏តាំង ឲ្យធ្វើបាបសង្កត់សង្កិនទៀត ហើយបង្គាប់ឲ្យយកទោសដល់ជីវិត ឥតជុំនុំមជុំរះ ពួកបារាំងទាំងប៉ុន្មាន ដែលប្រទះឃើញនៅក្នុង ស្រុកយួន ឃើញស្តេចយួនពព្រិតបទ់ឥតសប្បុរសដូច្នោះ នោះ រាជ្ការក្រុងបារាំងសែសក៏យល់ឃើ និងធន់អត់ទ្រាំមឲ្យស្តេចយួន ពព្រិតដូច្នោះត៏អង្វែងទៅទៀតមិនបាន លុះគិតស្រេចដូច្នោះ ក៏ចាត់កូប៉ាល់ចំម្បាំង ២ មកបាញ់បន្តក់គ្រាប់បែកលើស្រុកទូរ៉ាន ផែះផ្ទះសំម្បែងនាក់ស្រុកទាំងប៉ុន្មានអស់ ឯនាក់ស្តេចធៀវទ្រី កើតទុក្ខអន់ចិត្រហើយភ្យៀបារម្ភជាខ្លាំង ក៏អស់បុន្យទ៍ទូលអនិច្ចកម្ម ហើយមានកូនប្រុសនាមឈ្មោះទឺឌឹក ឡើងគ្រងរាជសម្បត្តិជា ដំណោរស្តេចអាពុក ក្នុងចុលស័ករាជ ១២០៩ ឆ្នាំមមែនព្តស័ក្យ នៅវេលានោះសេចក្តីដែរពព្រិតជាបឋមកម្ម គឺសង្កត់សង្កិន កុំហ៊ែងកុំហោកពាក្យពួកបារាំង ក៏រឹងរិតតែខ្លាំងឡើងនិងគិតគ្នា ពុំបានឡើយ





លុះដល់ ១០ ឆ្នាំ ត៏មកទៀត នោះរាជ្ការស្រុកបារាំងសែស ហើយនិងរាជ្ការស្រុកអាំងក្លេស និងធន់អត់ទ្រាំមពុំបាន ក៏ចាត់ កងទាព់ស្រុកទាំង ២ ជិះកូប៉ាល់ភ្លើង មកធ្វើទោសផ្តន្ទាអស់ ពួកចិន្ត ដែរវាពព្រិតបទអធម្ម រួបយួនវាធ្វើបាប ហើយបែះតែ ប្រមាទមាត់ជាពួកបារាំង ហើយនិងពួកបារាំងនាក់ដើរស្រម៉ុទ នោះកងទាព់នគរទាំង២ ចូលលុកវាយស្រុកក្រុងស្តេចក្រុងចិន្ត ប្រាប់ចិត្តទាំងអស់ទាំងនគរ ឲ្យដឹងខុសដឹងត្រូវ

លុះបានធ្វើទោសផ្តន្ទាស្រុកចិន្តរួចហើយ ពួកកងទាព់ អាំងក្លេស ក៏ត្រឡប់វិលទៅស្រុកវិញ នៅតែបារាំងសែស ដែរ កាលមុននោះបានធ្វើទោសផ្តន្ទាអស់ពួកយួន ក៏មកឈប់នៅ ស្រុកអាំងជូស៊ិន វាយកស្រុកទូរ៉ាន់ ក្នុងឆ្នាំមមីសំរឹទ្ធិស័ក្ក យកស្រុកព្រៃនគរក្នុងឆ្នាំមមែឯកស័ក្យ ហើយវាយកបានអស់ ទាំងស្រុកកូសាំងស៊ីនក្នុង ២ ឆ្នាំ ៣ ឆ្នាំ តមកក្រោយទៀតនេះ ព្រោះតែហេតុដូច្នេះ បានជាបារាំងសែសច្បាំង និងស្តេចយួន

១៨

១ ទៀតហេតុដូចម្តេច បានជាស្រុកខ្មែរយើង ក៏លែងភ្ញៀ បារម្ភនិងយួន រូបហេតុដូចម្តេចក៏បានជានៅតែស័ត្រូវ ១ បំណែក គឺស័ត្រូវនិងស្តេចសៀម នោះគាឈ្មោះព្រះបាទសម្តេចព្រះនរោត្តម ជាព្រះរាជបុត្រា ថ្លៃនៃព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួង) ដែរពាក្យរាស្ត្រទាំងពួង ហៅថាហ្លួងសុវណ្ណកោដ្ឋ បានឡើងស្នោរាជសម្បត្តិ គ្រងក្រុងកម្ពុជាខ្មែរយើង ក្នុង បុលស័ករាជ ១២២០ ឆ្នាំមមែឯកស័ក្ក នោះទ្រង់មានព្រះរាជ–ហារទៀបារម្ភក្រែងតែស្រុកបារាំងសែស មិនមកជួយទំនុកបំរុង ក្រុងកម្ពុជា នោះស្តេចសៀមនិងសង្កត់យកក្រុងកម្ពុជា រូប ពីនោះមកទៀតនៅមានព្រះអង្គម្ចាស់ស៊ីវត្ថា ដែរជាព្រះរាជបុត្រា ទី ៣ នៃព្រះបាទសម្តេចហរិរក្សរាមា ដែរមិនគួរគាប្បីយនិងត្រូវ ឡើងគ្រងរាជសម្បត្តិ ដំណាងអង្គសម្តេចព្រះវររាជបីតានោះគិត បាសបោរតាំងជាកងទាព់ ហើយរត់ទៅជ្រកក្នុងស្រុកសៀម

ឯស្តេចស្រុកសៀមបុនឲ្យតែម្ចាស់ស៊ីវត្ថា លើកកងទាព់ ចូលមកច្បាំង និងព្រះបាទសម្តេចព្រះនរោត្តម ក្នុងក្រុងកម្ពុជាវិញ



១៩

ដូចកាលនៃរព្រះរាជវង្សខ្មែរទាំងបុន្មាន ដែរក្បត់តាំងតែអំពីដើម រៀងមក នោះតែរត់ទៅជ្រកពឹងបុន្សសៀម ៗ តែងតែជួយកាន់ ជើងរៀងរៀបដរាបមក

នោះនៅវេលានោះ ក្នុងស្រុកខ្មែរក៏តាំងមានសឹកសង្គ្រាម ច្បាំងរាំងដល់ឡើងវិញ មិនតែច្បាំងពីព្រោះព្រះអង្គស៊ីវត្ថានោះ ឡើយ នៅមានពួកក្បត់តាំងខ្លួនជាអាចារ្យ អាក្បត់ ១ នោះ ឈ្មោះអាស្វា វាបំបាស់ខាងខែត្រ ទ្រាំង បន្ទាយមាស ពាម ហើយ លើកកងទាព់ លុកវាយយកស្រុកកំពត អា ១ ទៀត ឈ្មោះ ពោកំបោរ វាបំបាស់ខាងខែត្រ ក្រចេះ ឆ្លូង ត្បូងឃ្មុំ បាភ្នំ

ឯអាក្បត់ទាំងពីនាក់នោះ កាលកងទាព់ហ្លួងដេញប្រកិត ជិតនិងចាប់បានខ្លួនវា ៗ រត់ទៅ ចូលក្នុងដែនស្រុកកូសាំងស៊ីន ពួនក្នុងស្រុកពាមមាត់ជ្រូកលង់ហោរ ដែរនៅក្នុងអំណាចយួន ៗ វាទំនុកបំរុងអាក្បត់ទាំងពីនោះ ព្រោះយួនវាជាមហាស័ត្រូវនិង ខ្មែរយើងពីដើមមក ស្រេចហើយអាក្បត់ទាំងពី នោះវាត្រឡប់ចូល មកដើរភាគត្បាត បំបាស់បំបោរអស់រាស្ត្រប្រជា ក្នុងស្រុកខ្មែរទៀត

នៅរដូវដើមឆ្នាំ ចុលស័ករាជ១២២២ ឆ្នាំរកាទោស័ក ចៅហ្វាយស្រុកបារាំងសែស នៅស្រុកព្រៃនគរ ដែរបង្គាប់លើកងទ័ព ជើងគោក ជើងទឹកទាំងប៉ុន្មាន ចាត់នាម៉ឺនបារាំងសែស ១នាក់ ជិះកប៉ាល់មកចតនៅខេត្តកំពត ស្រេចឡើងទៅថ្វាយបង្គំគាល់ ព្រះបាទសម្ដេចព្រះនរោត្តម កាលទ្រង់គង់នៅព្រះ-បរមរាជវាំងឧដុង្គមានជ័យ ហើយយកសេចក្ដីក្រាបបង្គំទូល តាមផ្លូវរាជការ ថារាជការបារាំងសែសគិតសំរេចថា ត្រូវយកស្រុកកូសាំងស៊ីន ទុកជារបស់រាជការបារាំងសែស ព្រះបាទសម្ដេចព្រះ-នរោត្តម បានទ្រង់ជ្រាបដូច្នោះ ក៏មានព្រះរាជហឫទ័យសោមនស្ស និងរាជការបារាំងសែស យកស្រុកកូសាំងស៊ីន ផ្ដាច់ជារបស់បារាំងសែស លុះនឹងបាន១ខែតមក នោះព្រះបាទសម្ដេចព្រះ-នរោត្តម ទ្រង់តែងរាជទូតឲ្យទៅជួយអំណរ ចៅហ្វាយស្រុកបារាំងសែស នៅស្រុកព្រៃនគរ ឯសៀមកាលឃើញ ព្រះបាទសម្ដេចព្រះនរោត្តម ព្រមទទួលស្រុះស្រួលនិងបារាំងសែស ក៏អន់ចិត្ត





ដ្បិតបារាំងសែស ខាំងខ្លាំងជាងខ្លួន ហើយបានមកទំនុកបំរុងក្រុងកម្ពុជា ស្រេចហើយធ្វើសំបុត្រសន្យា បន់បយយួន ហើយនិងសៀម ពីស្រុកខ្មែរ ដាក់ស្រុកខ្មែរឲ្យនៅក្នុងទំនុកបំរុង រាជ្ជការបារាំងសែសដែរជាមហានគរធំអំវិញ ហើយហាមប្រាមនគរសៀម នគរយួន កុំឲ្យលើកទ័ពមកជន្លើម យកក្រុងកម្ពុជាតទៅ

តាំងពីបានរាជ្ជការបារាំងសែស មកទំនុកបំរុងកាលណោះ ក្រុងកម្ពុជាក៏បានសំបូណ៌សោភិនី ឥតមានសត្រូវឯណាមកបៀត-បៀនយាយី ហើយអាណាប្រជានុរាស្ត្រក៏រកស៊ីសុក្ខសាប្បាយ តាមដោយស្រុកចរិតពិត្យត្រង់ ពុំមានព្រួយទៀយភិតភ័យរត់លួន និងសឹកសាមសង្គ្រាមដូចទៀតឡើយ

កាលណោះបារាំងសែស បានធ្វើរាជ្ជការថ្វាយសម្ដេចព្រះនរោត្តម ជួយច្បាំងដេញចាប់អាចារ្យស្វា ពោកុំបោរ ឯខ្លួនពោកុំបោរ បាក់ទ័ពពីក្នុងខេត្តបាភ្នំ រត់ទៅដល់ស្រុកកំពង់ធំ ខេត្តកំពង់ស្វាយ ចាប់បានខ្លួនហើយប្រហារជីវិតនៅទីនោះ

~៦២

នៅវេលានោះក្នុងទន្លេសាប ទន្លេធំ ហើយនិងតាមឯងស្ទឹង មានតែទូកថ្លៃចិន្ត ទូក ២ ទូក ៣ ឯស្រូវថ្លៃ ៣ ហ៊ឹង ៥ កាក់ ដឹកដាក់ដល់ជើងកំពង់ បើទិញដល់ផ្ទះថ្លៃតែ ៣ ហ៊ឹង ២ កាក់កន្លះ ដ្បិតផ្ទះឆ្ងាយពីជើងកំពង់ ពីបាកដឹកនាំមតាមផ្លូវវែងដែរមិនគ្មានថ្នល់

ឯសំពត់ជាឱបទេសឯកថ្លៃអស់យ៉ាង រកនិងទិញប្រើការពុំបានទេ ហើយរោហគ្រានោះ សុតតែចិន្តរករកស៊ីក្នុងស្រុកខ្មែរយើងនេះបានបំណេញច្រើនណាស់ ហើយប្រាក់ក្នុងស្រុកខ្មែរទាំងបុត្ថានតៅផ្សែវាទាំងអស់ ហើយកាល្ណាវារកស៊ី បានប្រាក់ច្រើនវានាំមយកទៅស្រុកចិន្ត

ឯកប៉ាល់ភ្លើង ដែរមកដល់ក្នុងស្រុកខ្មែរមុនគេ នោះជាកប៉ាល់បារាំងសែស ខ្ញុំបានឃើញជាក់និងភ្នែក ហើយនៅចាំមច្បាស់ដល់ឥឡូវ កាលកប៉ាល់នោះមកដល់កំពង់ល្វង់ នាក់ស្រុកផ្អើលនៅឡោ ដ្បិតធ្លាប់ថាកប៉ាល់ ឥតក្ដោង ថែវ គ្រដឹង



~៦៣

ហើយបើកលឿនលើទឹកបាន មនុស្សប្រុសស្រីចាស់ក្មេង រត់ទៅមើលលាន់ ប្រព្វនប្រពាន់លើគ្នា ហើយធ្លាប់មិនយល់ថាដូចម្ដេចសោះ ស្រាប់តែឃើញរលកបែកពពុះខាងកន្សៃ ហើយលឿនពោរទឹកពីក្បាលជាះទៅបំបៀងសង្ខាង កើតជារលកបោកទៅខាងមាត់ច្រាំង នាក់ដែរមកមើលទាំងប៉ុន្មាន នោះអស្ចារលាន់មាត់ស្រែកហៃយ៉ៅហៃយ៉ា អឺកគ្រឹកគឹកកងរំពង មើលមិនដាក់ភ្នែកដៀសារឃើញ ផ្សែងចេញតាមបំពង់ភ្លើង ហើយឮសន្ធឹកគឹកគ័កគាក់ ពីខាងក្នុងកប៉ាល់នោះ ទាំងហ្លង់ក៏ស្ដេចមកជាមួយនិងនាម៉ឺនមុក្ខមន្ត្រី ហើយទ្រង់យាងទតមកពីមាត់កំពង់មកជាច្រើនម៉ោង ទ្រង់ព្រះសន្ធិះសង្ស័យនិងកប៉ាល់ ព្រោះមិនទាន់ជ្រាបហុធ្វើដូចម្ដេចខ្លះ អស់ទាំងនាក់ចាស់ប្រជាឈប់ឈរមើលរំពឹងគិត ហើយយល់ថានេះជាមនុស្ស នាក់ស្រុកនគរធំ គេមកដល់ស្រុកយើងហើយៗ មកជួយទំនុកបំរុងយើងស្រុកយើងនិងបានចំរើន ផ្លូវវិធីជាថ្មីឡើងទៀត ប្រហែលជានិងត្រឡប់បានឡើងជានគរធំមដូចខ្មែរដើមវិញ នោះជាប៉ុដើម

តាំងពីព្រះបាទសម្តេច ព្រះនរោត្តម សោ្យរាជរៀងមកដល
ឥឡូវនេះ នោះក្នុងស្រុកខ្មែរ វិធីខាងបំណិនវិជ្ជាក៏ចំរើនហើយឡើង
រុងរឿងជាងអំពីដើមនោះច្រើនណាស់ ហើយគ្មានសត្រូវមកបៀត
បៀន ពីព្រោះមានអ្នកមានបុណ្យអំណាច ដែរទំនុកបំរុងយើង
ឲ្យគ្រប់គ្រងពួកយួន នៅស្រុកកូសាំងស៊ីន ហើយសៀមក៏ខ្លាច
មិនហានមកបៀតបៀនទៀត តាំងពីវេលាគ្រានោះរៀងមក

ចូរអស់លោកអ្នកទាំងឡាយ នាម៉ឺនក្តី រាស្ត្រក្តី មើលហើយ
ពិចារណាគិតឲ្យស៊ប់ទៅឃើញឬទេ ស្រុកយើងសព្វថ្ងៃនេះ
ខុសគ្នានឹងកាល ៥០ ឆ្នាំមុន នោះឃើញខុសគ្នាដូចម្តេចខ្លះ
ហើយគិតកាលដែរស្រុកកើតចំបាំងរាំងជល់ ហើយស្រុកឥឡូវដែរ
បាននិងសុក្ខសប្បាយក្សេមក្សាន្តគ្រប់ទីកន្លែង ហើយប្រាក់ក៏មាន
សំបូរណ៍ក្នុងស្រុកខ្មែរយើង គ្រប់ផ្ទះសំបែងក៏មិនដែលដាច់ ខ្វះ
ច្បោះ! គង់តែងមានប្រាក់ច្បោះខ្លះរាល់ផ្ទះគ្រប់គ្នា ហេតុដែរ
បានសំបូរណ៍ទាំងនេះពីព្រោះត្បិត នោះឃើញថាសេចក្តីអត់ឃ្លាន





មិនសូវមាន តាំងតែពីកាលបារាំងសែស ចូលមកនៅក្នុងស្រុក
យើង ហើយស្រុកយើងក៏មិនយូរឡើយ សំបូរណ៍មានធនធាន
ហើយដូចជាខ្លួនតានេះអាយុស្ម ៨០ ឆ្នាំប៉្លាយហើយៗ ចាំមដំណើររឿង
ព្រេង នាំមកនិទានឲ្យកូនចៅទួតលួតលានៅឯក្រោយ ឲ្យដឹង
រឿងបារាំងសែសនេះ- កាលពីមុនដូចម្តេច តមកទៀតដូចម្តេច
មួយទៀតយើងសព្វថ្ងៃនេះ ចូរចាំមកុំភ្លេចសេចក្តី ដែរមនុស្ស
ពីដើមធ្លាប់រងលំបាក ទុក្ខវេទនានោះដូចម្តេចខ្លះ ហើយកុំភ្លេច
គុណបារាំងសែស តែនាំមាត់អាក្រក់គិតការទុច្ចរិតស្ងាត់កុំបាំង
ហើយ នោះវានាំឲ្យស្រុកនគរយើង ត្រឡប់ទៅកន្លែងដើមវិញ
ដូចកាលគ្រាដែរប៉ះតែកើតចំបាំង កុំសទ់អត់ឃ្លាន ២០ ឆ្នាំម្តង
១០ ឆ្នាំម្តង ជួនណាឃើញទាត់យួនមក ជួនណាឃើញទាត់
សៀមមក ម្តងទាត់មកពីស្រុកនេះ ម្តងទាត់មកពីស្រុកនោះ ហើយ
មានទាំងពួកចោរកំណាចកាចផ្តុំគ្នា លើកជាពួកជាកង លួច
ប្លន់កាប់ចាក់សំលាប់គ្នា ហើយដុតផ្ទះសំបែងវត្តអារាមវិនាសអស់

អើកាឡោះប្រហែល ៥០ ឆ្នាំមកហើយ នោះស្រុកយើង នោះគ្មានអ្វីសោះ សៀមហើយនិងយួនវាមកឆ្លៀតសង្កត់សង្កិន យើង ហៀប ៗ តែនិងស្មូនឈ្មោះផង ដល់មកឥឡូវនេះមានគេស្គាល់យើងទាំងពីភត់ ហើយសារពើផល់ជុំនួញយើង គឺ ស្រូវ ក្របាស.ម្រេច ហើយនិងត្រីពីក្នុងទន្លេព្រែកបឹង ស្ទឹង យើង ដែរ កាលពីដើម មិនសូវបាននាំមចេញទៅប្រទេសក្រៅ ហើយ ច្រើនតែឈ្មួញចិន្តចូលទិញ នោះឥឡូវនេះមានកប៉ាល់ភ្លើង នាំមទៅដល់ស្រុកម្ទីល ស្រុកចិន្ត ស្រុកយីពុន ស្រុកយ៉ាវ៉ា ហើយនិង ប្រទេសយូរ៉ុប

កាលដើមឡើយគេមិនទាន់ស្គាល់ស្រុកយើង ឥឡូវគេ មកពីគ្រប់ទិសដំបន់ មកមើលក្រុងភ្នំពេញ នគរធំម នគរវត្ស ហើយបើចង់ទិញទំនិញអ្វី ៗ មានគ្រប់ ប្រទេសក្រោមមេឃនេះ ក៏មានឲ្យទិញទាំងអស់ក្នុងស្រុកខ្មែរ កប៉ាល់សាលុបរបស់ចិន្ត ភ្លើង ឬរបស់បារាំងសែសខ្លះមានសព្វថ្ងៃនេះជាង ៦០ បើក





ជួញជួលជិះសំរោងទូក ទៅមកឃ្លុះហោរតាមទន្លេ បើទៅពី ភ្នំពេញទៅព្រៃនគរបំម៉្យផ្លូវតែ ២៤ ម៉ោង ឯស្រុកព្រៃនគរនោះ កាលដែរនៅក្នុងដៃយួន វាធ្វើជាម្ចាស់ស្រុកនោះ យើងមិន បានទៅសោះ

បើទៅពីភ្នំពេញទៅបាត់ដំបង ទៅក្របេះ បំម៉្យផ្លូវតែ ១២ ម៉ោងដល់ ដែរកាលពីដើមបំម៉្យផ្លូវតែ ៨ ថ្ងៃ បើទៅ តាមផ្លូវទន្លេធំម ទៅស្រុកលាវស្រុកខោង បំម៉្យផ្លូវសព្វថ្ងៃ តែ ២៤ ម៉ោង ហើយបើឡើងស្រុកល្អងប្របាង បំម៉្យផ្លូវមិនដល់ ២០ ថ្ងៃទេ បើទៅតាមផ្លូវស្រម៉ុទ ពីព្រៃនគរទៅស្រុកបាងកក តែ ៤ ថ្ងៃ បើទៅសឹង្គះពួរតែ ២ ថ្ងៃ ឯស្រុកលង្កា ដែរយើងស្គាល់ ឈ្មោះ ព្រោះសារតែគម្ពីរព្រះបាឡី នោះយើងមិនដែលទៅសោះ កាលពីដើមដ្បិទស្រុកឆ្ងាយណាស់ សព្វថ្ងៃនេះទៅតែ ៨ ថ្ងៃដល់ ឯស្រុកបារាំងសែសបំម៉្យផ្លូវតែ ២២ ថ្ងៃ ស្រុកខ្មែរយើងសព្វថ្ងៃ នេះមិនមែនជាស្រុកដែលឥតនណាស្គាល់ នាក់នគរទាំងពីភុព គេក៏មិនសល់និងស្គាល់យើង ហើយនគរណាដែរយើងមិន

ស្គាល់មិនដែលឮឡើយសោះ ឥឡូវនេះយើងស្គាល់ទាំងអស់ ហ្លួងយើងក៏បានស្តេចទៅស្រុកបារាំងសែស ហើយបានចូលទតស្រុកសឹង្គះបូរលង្កា និងព្រែកជីកធំ ដែរជៀបបារាំងសែសជីកទំលុះពីស្រមុទទិសឯកើតកាត់ទៅស្រមុទទិសឯឡិច ព្រែកជីកនោះជាផ្លូវស្រមុទធំ ក្នុង ១ ឆ្នាំមានកប៉ាល់ភ្លើងជាច្រើនពាន់បើកចេញចូលទៅមកមិនដែលដាច់ អស់ទាំងលោកសេនាបត្តីព្រះអង្គម្ចាស់ខ្សត្រី និងចៅជីតចៅចមអស់អ្នកក្នុងវាំង ក៏បានទៅឃើញស្គាល់ស្រុកបារាំង ឃើញក្រុងប៉ារិស ជាទីជ្បជុំនុំស្រុកបារាំងសែស ឯក្រុងប៉ារិសនោះជាក្រុងធំ និងគិតគន្នាត្រារាប់ពុំបាន បើរាប់តែរាស្ត្របំណុះស្រុក ក្នុងទីជ្បជុំនុំក្រុងប៉ារិសនោះ ប្រហែលជំនួនមនុស្ស ២ នគរស្រុកខ្មែរយើង ទើបប្រហែលនិងមនុស្សក្នុងទីជ្បជុំនុំក្នុងប៉ារិស ១ ហើយ ១ ទៀតកូនខ្មែរយើង ក៏បានទៅរៀនអក្សរបំណែះវិជ្ជា នៅស្រុកបារាំងសែស ហើយៗត្រឡប់មកវិញ ឡើងជាមនុស្សចេះដឹង នាំមដំណឹងរឿងរ៉ាវពីស្រុកបារាំងសែសយកមកនិយាយមុក្ខគួរឲ្យស្តាប់ ដ្បិទ





ស្រុកនោះជាស្រុកកាលមុន ៥០ ឆ្នាំ ខ្លួនខ្ញុំ អាពុកម្តាយ ជីតាជីដូនជីទួតលួតលាយើង មិនដែលឮឈ្មោះសោះ អើនេះគឺបារាំងសែសគេបើកលោក្យបំភ្លឺហ៍ឲ្យយើង បើគ្មានបារាំងសែស ម្ល៉េះសឹមយើងមិនដឹងការអ្វីជាច្រើនទេ គ្រាន្តែឃើញឋាមនុស្សស៍ ឃើញតែស្រុក ហើយឃើញតែបំណែះវិជ្ជាយ៉ាងខ្ពស់បុណ្ណឹង ឯឥឡូវនេះយើងដឹងស្គាល់ឋាបារាំងសែសនេះ ជាអ្នកមានរិទ្ធីអនុភាព មានប្រាជ្ញាឆ្លាតច្រើន ហើយការប្រើប្រស់អ្វីៗ តែនិងគ្រឿងម្ស៊ីនគ្រឿងចក្រ ឃើញរឹតតែពូកែឡើងទៀត, ជិតៗតែនិងមានរិទ្ធីចេស្តា ដូចទេវតា

គេយកទឹកជាច្រើនមកដាក់ក្នុងឆ្នាំងធំ ដុតភ្លើងដាំមឲ្យពុះៗជាខ្លាំង កុំឡាំងទឹកពុះនោះស្ទុះពីក្នុងឆ្នាំង ធាក់វិលកង់ដែរនៅលើផ្លូវដែក ឬធាក់ភ្លៅចក្រ វិលស្លាបចក្រក្នុងទឹក នៅខាងកន្សៃកប៉ាល់ អំណាចកុំឡាំងទឹកពុះនោះ គេក៏ប្រើឲ្យវិលកង់រទេះបើកល្បឿនឯង មិនចាំមបាច់ពឹងកុំឡាំងសេះ ឬសត្វ

ពាហនៈណោះឯទៀត ឲ្យអូសទង់ទាញឡើយ ឯកប៉ាល់ក៏បើក លឿនក្នុងទន្លេស្រម៉ុទ ដោយសារអំណាចទឹកពុះនោះដូចគ្នា មិនចាំមបាច់ប្រើក្តោងថែវក្រដឹងឡើយ

ពួកកូនខ្មែរយើង ដែរបានទៅស្រុកបារាំងសែស ហើយត្រឡប់មកវិញនិយាយថាបារាំងសែស វែះយកធ្យូងថ្មមកដុត ហើយបង្ហូតភ្លើងតាមបំពង់ទៅគ្រប់ផ្ទះសំល្បែង ឯភ្លើងដែរចេញពីបំពង់បង្ហូតនោះ ភ្លឺហ៍ដូចភ្លើងចង្កៀងប្រេងកាត ក្នុងស្រុកខ្មែរយើងនេះ កាលដើមអុបចន្លុះ ប្រដែះទៀនក្រមួន ឥឡូវនេះរាល់ផ្ទះអុបចង្កៀងប្រេងកាត ឯប្រេងកាតនោះ ជាប្រេងអន្លង់កើតពីក្នុងដី នៅប្រទេសឆ្ងាយណាស់ ដែរកប៉ាល់បារាំងនាំយកមកលក់ក្នុងស្រុកខ្មែរ ។ ឯចង្កៀងទាំង ៨០០ ដែរបំភ្លឺហ៍ ក្រុងភ្នំពេញសព្វថ្ងៃនេះ មិនមែនជាភ្លើងដែរដុតធ្យូងថ្ម បង្ហូតតាមបំពង់ទេ ។ ភ្លើងនេះជាភ្លើងអគ្គិសនី មានបន្លឺហ៍ដូចផ្លេកមន្ទល់កន្ទុបអាកាស ដែរបារាំងគេបែះផ្សំមធាតុ យកកុំប៉ាញធ្វើឲ្យរត់តាមខ្សែលួស





អើកាល ៥០ ឆ្នាំមុននេះ យើងមិនទាន់ដឹងជាបារាំងគេមានខ្សែលួសរែទៅមករកគ្នា ហើយស្ដាប់គ្នាបានពីចំងាយ ឥឡូវយើងឃើញថាគេនិយាយគ្នា ពីស្រុកវៀងច័ន្ទ មកភ្នំពេញ ពីភ្នំពេញទៅលួងប្របាង ពីព្រៃនគរទៅហាន់ណោយ ទៅស្រុកហ្វេ ទៅបាងកក ទៅស្រុកចិន្ត ហើយទៅដល់ស្រុកបារាំងសែស និង តែក្នុងពីបីមីនុតស្ដាប់ដំណឹងដឹងការទៅវិញទៅមក ដំណឹងដែររត់តាមខ្សែលួសនោះ រហាស់ស្មើនិងជីវិតដែរគិត អើបើគិតសព្វគ្រប់ទៅ ឃើញថាបារាំងគេមានគុណនិងយើង មិនតែប៉ុណ្ណោះនៅមានគុណច្រើនជុំពូកទៀត បារាំងសែសនេះគេមានប្រាជ្ញាឆ្លាតគ្មានទុញទាល់សល់និងអ្វីសោះ គេនាំយកនៅរបស់ដ៏ប្រសើរមកបង្ហាញបំភ្លឺហ៍យើង

១ ទៀតគេនាំយកមុស៊ីនហិបច្រៀង ចិតសំម្លេងភាសាដូចមនុស្សច្រៀងនិយាយគ្នាមែនទែន តាមតែទំនើងបិត្រណាចង់ស្ដាប់ចុះ ហើយមានកុនស្រមោលផ្ទះរូប វិស្សដូចឃើញស្រុក

ប៉ារាំងសែស ផ្លូវជាមនុស្សម្នាដើរទៅមកដូចរបស់ដែរគេឃើញ ក្នុងស្រុកបារាំងសែសក្រុងប៉ារិសដូចម្ដេច នោះយើងនៅតែស្រុកខ្មែរ ឃើញវិស្សដូចយើងបានឃើញស្រុកបារាំងសែសខ្លួនយើង

គេប្រើធ្វើគ្រឿងថតរូប បើដូលតែពីបីរៀល បានរូបរបស់ខ្លួនយកមករក្សាទុក ហើយជាប្រយោជន៍បានរក្សារូបអាពុកម្ដាយទុកតទៅមុខ ឲ្យកូនដឹងស្គាល់ជារូបជីតាជីដូន ដែរស្លាប់ជាអង្វែងរាប់រយឆ្នាំមកហើយនោះ

គេនិយាយថាបារាំងសែស សព្វថ្ងៃនេះបេះហោះលើអាកាស ដោយអំណាចយន្តគោមហោះៗលឿន ដូចសត្វហើរ ពាក្យនេះពិតមែន បើមិនជឿសួរមើលចុះអែះ ថាបើបារាំងទាល់បំណែះហើយតទៅមិនយកយន្តហោះនោះមកឲ្យយើងឃើញទៀត

ព្រះបាទសម្ដេច ព្រះនរោត្តមជាអម្ចាស់ផែនដី នគរយើង ព្រះអង្គបានផ្ញើរាជ្ការផែនដីទាំងបុន្មាន ឲ្យបារាំងសែសគ្រប់គ្រងតាងព្រះនេត្រ ព្រះឱស្ឋជាមួយនិងសេនាបត្តី ហៅហ្វ្រស្រុក





បាទឡាត់សុភាយោក្សាត់ ហើយនិងពួកនាក់រាជ្ការខ្មែរជាច្រើនពាន់ ដែរធ្វើរាជ្ការ នៅក្នុងបង្គាប់រេស៊ីដង់បារាំងសែស ឯប្រាក់ទាំងបុន្មាន ដែរបានមកពីពន្ធគ្រប់ជំពូក និងប្រាក់ដែរលោះថ្ងៃធ្វើរាជ្ការនោះយកមកចាយ ប្រើការជាប្រយោជន៍ បំរើនព្រះរាជកាទីទាំងអស់ បានប្រាក់នោះដែរយកចាយ រៀបចំមតែងក្រុងភ្នំពេញដែរសព្វថ្ងៃនេះ បានកើតឡើងជាក្រុងល្អរុងរឿង ដែរពួកខ្មែរទាំងបុន្មាននៅខេត្តក្រៅ គេតែងចូលមកមើល និយាយសរសើរគ្រប់គ្នា ហើយនាក់ប្រទេសក្រៅក៏មានចូលមកមើលលេងនៅក្រុងភ្នំពេញជាច្រើន ក្រៅពីរៀបចំតែងក្រុងភ្នំពេញនោះរាជ្ការនៅរៀបចំតែងដែរ ទីជុំនុំមរួមខេត្តដប់អន្លើហ៍ទៀត

ហើយធ្វើថ្នល់ធ្វើស្ពានផ្លូវ ឲ្យរទេះប៉ះទៅមកដោយស្រួល ហើយនៅគិតនឹងធ្វើផ្លូវថ្នល់ ឲ្យគ្រប់ទីដីបងក្នុងស្រុកខ្មែរ ឲ្យបានដឹកតាមជុំនួញទំនិញកាត់ទៅលក់ ក្នុងភូមធំមៗ ដោយងាយ ហើយបានឆាប់ក៏ឆាប់ ឯសោហ៊ុយដឹកទាំមទំនិញទៅឯផ្សារធំមកហោក

១ ទៀតគេរៀបរាយថាគិតធ្វើរទេះភ្លើង ក្នុងរទេះ ១ ទាញ យោងបានរទេះ ១០ កាត់ផ្ទុកទំនិញ ហើយនិងនាក់ដំណើរ ពី បាត់ដំបងមកស្រុកភ្នំពេញទៅព្រៃនគរ គេរៀបរាយគិតថានឹង ធ្វើផ្លូវរទេះភ្លើង ១ ទៀតកាត់ទៅលាវទៅយួន ហើយនិងស្រុកសៀម ប៉ុន្តែផ្លូវរទេះបរថភ្លើងនោះ និងធ្វើឲ្យទាន់ឆាប់ភ្លាមនោះមិនបានទេ ប៉ុន្តែគេថានិងធ្វើឲ្យបាន ហើយក្នុងរវាងមុន ២៤ ឆ្នាំនេះ នោះ ស្រុកខ្មែរនិងមានផ្លូវរថភ្លើងបទៅមកជាប់គ្នា និងនគរដែរនៅ ជុំវិញយើង ឯផ្លូវទៅស្រុកយូរ៉ុបស្រុកចិនស្រុកយីពុន នោះ មានផ្លូវកប៉ាល់ភ្លើងកប៉ាល់ជំនួញស្រាប់ហើយ កាលណាមានផ្លូវគ្រប់ បរិបូណ៌នោះស្រុកខ្មែរយើង ក៏នឹងត្រឡប់ឡើងជាទីប្រជុំផ្លូវ ជំនួញធំ ១ ហើយនគរក៏និងបានជាធំថ្កុំថ្កើងឡើង សំគួរ តាមលំដាប់ស្រុកបុរាណខ្មែរដើមវិញ ពួកអំបូរកូនចៅខ្មែរ ដែល ជំណាវង្សត្រកូល មិនបង់កំណើតជាតិ ដោយសារក្រឡាប់ ឡើងបានជាពួកនាក់នគរធំមនិងគេវិញ





រាំងទាត់ទឹងចំបាំងរាំងផល់ យើងក៏អស់មានអំពាល់ សេចក្តី ព្រួយបារម្ភ ដ្បិតបារាំងសែស គេគិតតែបង្រៀនប្រដៅបំណោះ វិជ្ជាការ ឲ្យយើងរួបខ្លួនជាខ្មែរនាក់ជា ហើយខ្លាំងពូកែ គេសង់ សាលាបង្រៀនអក្សរបារាំងគ្រប់ទីកន្លែង ហើយគេទំនុកបំរុងវត្តអារាម ដែលបង្រៀនអក្សរសាស្ត្របាឡីខ្មែរ ហើយគេចែករង្វាន់ឲ្យកូនសិស្ស ណាដែលខំរៀន ហើយគេសុំតែគ្រប់គ្រងយើង ជាមួយនិង នាម៉ឺនខ្មែរណា ដែលមានចិត្តស្លូតត្រង់ ហើយរើសយកខ្លួនឲ្យធ្វើជា នាម៉ឺនឲ្យបានចំរើនក្នុងនគរ ហើយឲ្យយើងរាស្ត្រខ្មែរទាំងប៉ុន្មាន បានចំរើនសេចក្តីសុខគ្រប់គ្នា ឯខ្លួនតានេះចាស់ហើយ គិតរំពឹង ច្រើនៗទៅ ឃើញទៅដល់របស់ដែរខ្លួន បានឃើញកាល នៅក្មេង គិតទៅដល់របស់ ដែរបានឃើញកាលខ្លួនធំមហើយៗ គិតមកដល់របស់ដែរភ្នែកខ្លួនឃើញសព្វថ្ងៃនេះ គិតឃើញម្តង ទៅ មុខគួរឲ្យកោតខ្លាចបារាំងសែសនេះណាស់ មកកោតនិង មានចិត្តសង្វាតឧស្សាហ៍ប្រាជ្ញាឆ្លាត ឯខ្មែរយើងឃើញខ្ជិល ប្រអូស ក្នុងខ្លួន ក្នុងចិត្តបន្តិច ឯបារាំងសែសចូលកូនចៅមើល

គេបុះឃើញទេ តាំងពីប្រមាណ ១៥ ឆ្នាំរៀងមក ដែរគេស្ដី
រាជ្ការគ្រប់គ្រងស្រុកយើង ដែរមកដល់សព្វថ្ងៃនេះ គេធ្វើបាន
សេចក្ដីវត្តរះ ហើយគំនិតគេល្អ គេគិតតែឲ្យយើងចំរើនបាន
សេចក្ដីសុខ ឲ្យយើងចំរើនមានទ្រព្យសម្បត្តិ ហើយនិង
រៀបចំមទីដីស្រុកយើងឲ្យរបបរៀបរយ តាមដៀវគ ដៀស្មើរ
ហើយគេប្រំបាត់មិនឲ្យមានខ្ញុំកន្លះ នាក់ងារអគ្គ្រាក់ត្រមាក់ជៀវគុន
គេបែកដីឲ្យយើងរាល់គ្នា ធ្វើស្រែចំការរកស៊ី សព្វថ្ងៃនេះ
ដីរបស់អ្នកណា នាក់និងធ្វើជាម្ចាស់ដី ហើយដល់ស្រែចំការ
ច្បារដំណាំ យើងក៏លក់បានថ្លៃ ជាងពីដើម

១ ទៀតមុក្ខឲ្យសរសើរបារាំងនេះ បិត្រគេត្យក៍ដា និង
នាក់កុសទទូរគត់ នាក់មានជុំម្ងឺហ៍រោគាព្យាធិម្ល៉េះៗ គេបាត់
គ្រូពេទ្យដាក់ឲ្យនៅគ្រប់ទីរសុំជង្សរូមខេត្ត ឲ្យចាំមបីបាច់រាក្សា
មើលថែទាំមនាក់ជុំម្ងឺហ៍ទាំងនោះ ក៏ឃើញថាបិត្រគេល្អមែន
ហើយ ឯយើងខ្មែរដែរនិងដឹងគុណគេនោះ គឺយកចិត្រឈឺឆ្អាល





ជួយគេតាមគំនិតដែរគេគិតធ្វើការអ៊្យៗ ឯសេចក្ដីដែរឈឺឆ្អាល
ជួយការគេនោះ ទុកប្រៀបដូចជាយើងស្រឡាញ់ស្រុកយើង
ធ្វើរាជ្ការតបស្នងសងគុណគេរយើង

កាលដែរបារាំងសែសទើពមកដល់នោះ ឆគឺះយើងកាន្ត
គួបណាស់ទៅហើយ នៅតែពីត្រឹមខេត្រពោធិ៍សាត់ ទៅទល់និង
ព្រែកជីកខេត្តពាម ដែរភាសាយួនវាឲ្យឈ្មោះហៅព្រែករិញពេ
នៅសល់ពីត្រឹមខេត្រសំបូរណ៍ ទៅទល់និងខេត្តរំដួល ហើយនិង
ស្រុកត្បូងស្មៀង ទៅទល់និងមាត់ស្រម៉ុទខាងកើត ហើយខាងទាំង
ខេត្តកោះកុង ដែរបានទៅសៀម នោះមិនដឹងជាធំពេកីរដូចម្ដេច
ក៏បានជាកាន្តតូចទៅដូច្នោះ ឯសព្វថ្ងៃនេះស្រុកយើងខ្មែរត្រឡប់
បានឡើងជាធំមវិញ កាលដែរបារាំងសែសទើពមកដល់នោះ
មិនបានធំមបុណ្ណឹងទេ សព្វថ្ងៃនេះបានធំមអាក់កន្ទលថែមទៀត

កាលក្នុងរាជ ព្រះបាទសម្ដេច ព្រះហរិរក្សរាមា
(ព្រះអង្គឌួង) ឬកាលក្នុងរាជ ព្រះបាទសម្ដេចព្រះនរោត្ដម

(ហ្លួងសុវណ្ណកោដ្ឋ) នោះស្រុកយើងខ្មែរ ក៏មិនទាន់បានធុំម បុណ្ណឹង ឯសៀមពីព្រោះតែបារាំងសែសគេស្ដីន បានជាវាប្រគល់ខេត្របាត់ដំបង មង្គលបូរី ស៊ីសុផុន សៀមរាប ដែរនៅខាងម្ខាងទន្លេសាបទាំងប៉ុន្មានឲ្យយើងវិញ រីឯខេត្រកោះកុងដែរនៅត្រើយមាត់សមុទ្រខាងឡិច ក៏សៀមវាប្រគល់មកឲ្យយើងវិញដែរ ឯខេត្រទន្លេរពៅ មូលប្រៃ ដែរនៅជាខាងជើងនគរខ្មែរយើង ក៏សៀមវាប្រគល់មកឲ្យយើងវិញ ១ ទៀតស្រុកបារាំងសែសគេយកស្រុកលាវបានមកពីដៃសៀម ហើយគេប្រគល់ខេត្រស្ទឹងត្រែងមកឲ្យខ្មែរវិញ បើគ្មានស្រុកបារាំងសែសម្លេះសំមយើងនិងយកខេត្រទាំងនោះ មកបន្ចូលក្នុងស្រុកខ្មែរវិញមិនបានឡើយ កាលនៅក្នុង ៥០ ឆ្នាំមុន យើងមានបាបកាំមវាផ្ដាច់យើង ឲ្យសួនឈ្មោះទៅជាបំណុះសៀម ហើយទីដីនគរយើងក៏ទៅជាដីសៀម រីឯសព្វថ្ងៃនេះខេត្រយើងក៏បានធំម ហើយរឹតតែធំមឡើង ឯនគរយើងក៏ឡើងជាមហានគរធំម ដូច្នេះយើងមានក្ដីទំមនឹសាហ៍ធ្វើការបាន្ដិច និងអាលបានឡើងស្មើរនិង





នាក់ស្រុកនគរធំមនិងគេ ។ អើយើងបានមានបុគ្គលសំណាងទាំងម្លេះនេះដោយសារបារាំងសែស បើគ្មានគេប្រហែលជាយើងមិនកើតជាអ្វីសោះ សព្វថ្ងៃនេះបារាំងសែស គេមានគុណនិងយើងបានជាយើងមានសំណាងបុណ្ណឹង ហេតុដូច្នេះទើបបានជាតាក់គិតតែងជាទីទានតាមរឿងដំណើរ ដែរមានរៀងមកទុកទូន្មានបន្តូលបិត្រអស់នាក់ទាំងពួង ដែរជាសាស្ន៍ខ្មែរដូចគ្នា ឲ្យស្រឡាញ់រាប់អានទុកចិត្របារាំងសែស ដោយស្មោះត្រង់ កុំញាញើតគិតរាមុក្ខរក្រោយឡើយ ដ្បិតបារាំងសែសនេះជាមិត្រមេត្រី ជាពុំនិង ហើយជាគ្រូរយើងផង ។

សេចក្ដីដែរបានតែងជាបរិយាយ រៀបតាមដំណើរមកនេះ ដ្រៀងខាតខុសលើសលោះ ឬពុំគោរព្យ៍សំមពីរោះដោយបទវាក្យអាត្តសេចក្ដី សូមអស់លោកនាក់ទាំងឡាយអត្ថៃយទោស ដោយសារប្រាជ្ញាស្មារដីតិចបំណែះក៏ឱបឡ ហើយខ្ញុំបាទសឺរាមានតែចិត្របរិសុទ្ធស្លូតត្រង់ ស្រឡាញ់ទឹកដីរបស់ខ្លួន ទើបតែង

តាមដំណើរទុកឲ្យចាក់ក្រៀមមើលស្លាប់ទៅ ព្រោះបិត្រសង្ឃឹមថាវាក្លាហានរាំងសែស ទំពាត់បែងរៀបបំមនគរយើង ឲ្យឡើងជានគរធំ មានបុត្របំណាច់កូនចៅទៅឯក្រៀ គង់តែនឹងផងព្រលើញតទៅ បានជាតែងគិតធ្វើសេចក្ដីប្ដេះ នេះព្រោះតែបិត្រខ្ញុំគិតតែខាងល្អ បើគួរពុំគួរសូមអភ័យទោស

តែងក្នុងបុលស័ករាជ ១២៦៩ ឆ្នាំមមែឆព្វស័ក្ក កាលតាអាយុស្មបាន ៨០ ឆ្នាំឆ្នាំហើយ ។ះ៚